# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ឈ្មោះ សោម ម៉េត (K 05435)

## សម្ភាសជាមួយឈ្មោះ សោម ម៉េត អាយុ៤៨ឆ្នាំ ភេទប្រុស ម្ចាស់ប្រវត្តិរូប

## មុខងារសម័យខ្មែរក្រហមៈ កងការពារនៅមន្ទីរស-២១

## រស់នៅភូមិកំពង់សំបួរលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល

## ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៣

## សម្ភាសដោយៈ ផាន់ សុជា

## សរុបៈ ៣៥ទំព័រ

### ផ្នែក «ក»

សុជាៈ ពូឈ្មោះអីដែរពូ?

ម៉េតៈ ខ្ញុំឈ្មោះ សោម ម៉េត ។

សុជាៈ សោម ម៉េត?

ម៉េតៈ បាទ!

សុជាៈ មកដល់រាល់ថ្ងៃពូអាយុប៉ុន្មានដែរ?

ម៉េតៈ ៤៨ឆ្នាំ ។

សុជាៈ ប្រពន្ធពូឈ្មោះអីដែរ?

ម៉េតៈ ឈៀ រិម៉េន ។

សុជាៈ ពូមានកូនចៅប៉ុន្មាននាក់រាល់ថ្ងៃ?

ម៉េតៈ ៥នាក់ ។

សុជាៈ ឪពុកម្ដាយពូឈ្មោះអីដែរ?

ម៉េតៈ ឪពុកស្លាប់ហើយ ។

សុជាៈ ឈ្មោះអីដែរ?

ម៉េតៈ សោម សុខ ។

សុជាៈ សោម សុខ ។ ចុះម្ដាយ?

ម៉េតៈ ម្ដាយឈ្មោះ អ៊ុក ញ៉ម ។

សុជាៈ គាត់នៅរស់ដែររាល់ថ្ងៃ?

ម៉េតៈ គាត់នៅរស់ ។ ប៉ុនជរាហើយ ។

សុជាៈ ភូមិដែលពូនៅរាល់ថ្ងៃ គេហៅភូមិអីដែរ?

ម៉ែតៈ ភូមសំបួរលើ ។

សុជាៈ ឃុំ?

ម៉ែតៈ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ។

សុជាៈ ចុះស្រុកកំណើតពូ?

ម៉ែតៈ ស្រុកកំណើតនៅភូមិព្រែកស្បូវ ។

សុជាៈ ឃុំ?

ម៉ែតៈ ឃុំព្រែកស្បូវ ស្រុកកោះធំ ។

សុជាៈ ពូមៅនៅនេះតាំងពីឆ្នាំណា?

ម៉ែតៈ ឆ្នាំ ៨០ ។

សុជាៈ ហេតុអីបានជាពូមៅនៅនេះ ។

ម៉ែតៈ ខ្ញុំមៅមានគ្រួសារនៅនេះ ។

សុជាៈ អញ្ចឹងគ្រួសារពូគាត់នៅនេះ?

ម៉ែតៈ បាទ!

សុជាៈ អញ្ចឹងពូការនៅឆ្នាំហ្នឹងដែរ ឆ្នាំ៨០?

ម៉ែតៈ បាទ!

សុជាៈ កាលពីការហើយរហូតមកដល់ឥឡូវ ពូមានប្រកបរបរធ្វើអីដែរ?

ម៉ែតៈ ធ្វើស្រែចម្ការ

សុជាៈ ចុះក្រៅពីធ្វើស្រែចម្ការ ពូមានធ្វើអីទៀតទេ?

ម៉ែតៈ អត់មានធ្វើអីទេ ។

សុជាៈ ចុះពូថាចេះជាងឈើ ?

ម៉ែតៈ អូរ! ជាងឈើខ្ញុំគ្រាន់តែចេះជួយៗ បងប្អូនស្រុកភូមិ ។

សុជាៈ ចុះពូមានចម្ការដែរ?

ម៉ែតៈ មាន គេចែកបានដីមាំកន្លែង ។

សុជាៈ ចុះចម្ការ ដាំអីគេដែរ?

ម៉ែតៈ ដាំពោត ដាំដំឡូង ស្រូវ ។

សុជាៈ ចុះដីស្រែផ្សេងទៀត?

ម៉េតៈ ផ្សេង ខ្ញុំចែកអត់បានផង ។ ជួនកាលជួលដីគេធ្វើ ។

សុជាៈ ចុះម៉ាឆ្នាំៗ ស្រូវបានហូបគ្រប់គ្រាន់ដែរ?

ម៉េតៈ អត់គ្រប់ ជួនកាលបាន......................ហ្នឹងហើយ រួចម៉ាឆ្នាំ ។

សុជាៈ ចុះបើអត់គ្រប់អញ្ចឹង យើងបានអីហូបទៅ?

ម៉េតៈ ចេះតែរកទៅ ជួនកាលទៅស៊ីឈ្នួលគេ ធ្វើការងារឲ្យគេទៅ ស៊ីឈ្នួលភ្ជួរដីឲ្យគេ ។

សុជាៈ ចុះដីស្រែដាំសណ្តែតដី ដាំពោតអីនោះ?

ម៉េតៈ ដាំពោត ជួនកាលបានមៅហ្នឹងលក់បន្តិចបន្តួចអញ្ចឹងទៅ ឲ្យជ្រូកស៊ីទៅ ។

សុជាៈ ចុះប្រពន្ធពូធ្វើអីដែរ?

ម៉េតៈ អត់មានធ្វើអីទេ ធ្វើស្រែចម្ការដូចគ្នា ។

សុជាៈ ចុះដីចម្ការល្មុត?

ម៉េតៈ អត់មាន ។ រកដាំដែរ តែមិនដឹងដាំម៉េចដីតូចមួយ ។ កាលហ្នឹងចែកបានជាមួយប្រពន្ធខ្ញុំ កូនវាអត់ទាន់មានកាលហ្នុង ។

សុជាៈ ដីដែលចែកហ្នឹង ពីណាគេចែកឲ្យទៅ?

ម៉េតៈ របបកម្ពុជា ។ ដូចកាលបែកភូមដីវានៅរួម នៅសាមគ្គីដែរហ្នឹងណាស់ ។

សុជាៈ បាទ!

ម៉េតៈ ការហើយអត់មានមុខរបរអី ដើររើសអេតចាយ ធាក់ស៊ីក្លូអីនាយអាយទៅ ។

សុជាៈ បាទ!

ម៉េតៈ បាន១០០០០, ២០០០០ អីមៅផ្ទះវិញ ។

សុជាៈ ចុះពូកូនចៅពូបានរៀន បានសូត្រគ្រប់គ្នាដែរ?

ម៉េតៈ បាទ! បានរៀនដែរ អាខ្លះបានថ្នាក់ទាបទៅ ។

សុជាៈ ចុះបានការងារធ្វើដែរទេ?

ម៉េតៈ កូន មាននៅរោងចក្រមួយដែរ ។

សុជាៈ មានបានជួយដល់ពូបានច្រើនដែរអេះ?

ម៉េតៈ ជួយខ្ញុំម៉ាខែៗជួនកាលទៅបាន៣០ដែរ គ្រាន់ថាបានដោះស្រាយជីវភាពបានខ្លះដែរ ។

សុជាៈ ពូ និយាយរឿងពូវិញ មានបងប្អូនប៉ុន្មាននាក់ដែរ?

ម៉េតៈ បងប្អូនខ្ញុំទាំងអស់៥នាក់ ប៉ុន្តែស្លាប់អស់៣នាក់ ។

សុជាៈ អញ្ចឹងនៅរាល់ថ្ងៃនៅសល់ប៉ុន្មានដែរ?

ម៉េតៈ  នៅតែពីរ  អាប្អូនពៅមួយនៅជាមួយម្ដាយ

សុជាៈ  ពូដែលទៅលេងម្ដាយដែរ?

ម៉េតៈ  ទៅដែរ ។

សុជាៈ  ហើយពូកូនទីប៉ុន្មានដែរ?

ម៉េតៈ  ខ្ញុំបន្ទាប់ពៅគេ  ទី៤ ។

សុជាៈ  ចុះបងបន្ទាប់ពូឈ្មោះអីដែរ?

ម៉េតៈ  ឈ្មោះ  សោម  តយ ។  ហ្នឹងទី១

សុជាៈ  ចុះទី២

ម៉េតៈ  ទី២  ឈ្មោះ  កេង  ស្លាប់ហើយ ។

សុជាៈ  ស្លាប់កាលពីសម័យណាដែរ?

ម៉េតៈ  ទើបតែស្លាប់ឥឡូវនេះដែរ ។

សុជាៈ  ចុះហ្នឹងប្រុសស្រី?

ម៉េតៈ  ប្រុសទាំងអស់  ខ្ញុំអត់មានស្រីទេ ។

សុជាៈ  ចុះ ។

ម៉េតៈ  បងបន្ទាប់ខ្ញុំវានៅ

សុជាៈ  ហើយគាត់ស្លាប់នៅឯណាដែរ?

ម៉េតៈ  ស្លាប់នៅគុកទួលស្លែង ។

សុជាៈ  គាត់ធ្វើអីបានជាទៅស្លាប់នៅទួលស្លែង?

ម៉េតៈ  វា  កាលពីឆ្នាំ៧២  ៧៣  កាលហ្នឹងវាមិនចាប់យើងដំរៀនទៅធ្វើទាហាន ។

សុជាៈ  បាទ!

ម៉េតៈ  ទាហានកាលហ្នឹង  ថាទាហានខ្មែរក្រហមក៏បាន  ទាហានរណសិរ្សក៏បាន  ហើយកាលហ្នឹង  ដល់បែកភ្នំពេញ  ៧៥ហ្នឹង  ពុស្សូរថាវាបញ្ជូនទៅវាលយន្តហោះកំពង់ឆ្នាំង ។

សុជាៈ  បាទ!

ម៉េតៈ  ពុតែដំណឹងទេ ។  ដល់ហើយ  ដល់ឆ្នាំពាក់កណ្ដាល៧៨  គេហៅចាប់មកដាក់គុកទួលស្លែង ។  ខ្លួនឯងនៅហ្នឹងដែរ  ប៉ុនអត់ដឹងគេថាបង  ព្រោះថាភារកិច្ចវាខុសគ្នា ។  ដូចថាខ្ញុំនៅទីតាំងហ្នឹងអញ្ចឹងប៉ុនមិនអាចទៅបានដើរជាមួយអ្នក.........................អ្នកអីណាមួយផ្សេងគ្នាទេ ។

សុជាៈ  ចុះពេលណាដែលពូបានដឹងថាគាត់ស្លាប់នៅទួលស្លែង?

ម៉េតៈ ហ៊ុយ អ្នកនិយាយប្រាប់ ។

សុជាៈ ហ៊ុយ ហ្នឹងពីណាដែរពូ?

ម៉េតៈ បាស់!

សុជាៈ ហ៊ុយ ហ្នឹងគាត់ធ្វើអីដែរ?

ម៉េតៈ គេនៅប្រធានក្រុមនៅគុកទួលស្លែងហ្នឹង ។

សុជាៈ គាត់ទទួលផ្នែកអីគេដែរ ។

ម៉េតៈ ផ្នែកកងការពារ ប៉ុនភារកិច្ចគេវាគ្រប់ផ្នែកទាំងអស់ យើងវាមិនអាចដឹងគេធ្វើអីៗទេ ។

សុជាៈ ហ៊ុយ ហ្នឹងសព្វថ្ងៃនៅរស់ទេ?

ម៉េតៈ នៅរស់តើ ធ្វើការជាមួយខ្ញុំដែរនៅភ្នំពេញជាមួយគ្នាដែរ ។ ស្រុកកំណើតខ្ញុំ នៅកំពង់គរ ហើយទៅវាមានប្រពន្ធនៅព្រែកកុកយើង ឃុំព្រែកស្តី ។ ទៅទាំងអស់ឃើញមៅវិញតែខ្ញុំ ម៉េងគ្រី ហ៊ុយ ហើយឈ្មោះអី ឃីនៅកោះខែលនេះ ។ ឃី ហ្នឹងក៏វាមានការងារផ្សេង ដូចជាស្មៀន ។ ដូចខ្ញុំអ្នកកងការពារអញ្ចឹងទៅ ។

សុជាៈ ពូ ពូនិយាយពីដើមមៅវិញ?

ម៉េតៈ តាំងពីខ្ញុំចូលធ្វើបដិវត្តមៅអ្ហេស ។

សុជាៈ ចូលបដិវត្តនៅឆ្នាំណា?

ម៉េតៈ ចេញពីបន្ទុកគ្រួសារអ្ហេះ?

សុជាៈ បាទ!

ម៉េតៈ និយាយទៅដើមឆ្នាំ៧៣ ។

សុជាៈ កាលពូចេញទៅហ្នឹងពូទៅតែម្នាក់ឯង ឬក៏មានគេចេញទៅច្រើនគ្នាដែរ?

ម៉េតៈ ចេញទៅហ្នឹងគឺថាខ្ញុំ កាលមុនខ្ញុំចេញទៅ ខ្ញុំនៅវត្ត ។ ដល់ពេលឪពុកគាត់ស្លាប់ទៅ ខ្ញុំមៅនៅផ្ទះវិញ ។

សុជាៈ បាទ!

ម៉េតៈ ដល់នៅផ្ទះ ភូមិឃុំសង្កាត់គេហ្នឹង គេមៅដឹកនាំយើងឲ្យចូលធ្វើបដិវត្ត កាលហ្នឹងណាស់ ។

សុជាៈ បាទ!

ម៉េតៈ ហើយម្តាយគាត់អត់ឲ្យទៅ ។ ហើយខ្ញុំកាលនោះនៅអាយុតូចដែរ កាលហ្នឹងនៅអាយុជាង១០ឆ្នាំ ។

សុជាៈ បាទ!

ម៉េត: ទៅហ្នឹងគេ............................យើងថានៅត្រឹមភូមិ ត្រឹមឃុំសោះហ្នឹងណាស់ ។

សុជា: បាទ!

ម៉េត: ដល់ហើយយើងនៅត្រឹមភូមិ ត្រឹមឃុំ គេបញ្ជូនយើងទៅ........ទៀត ។ ដល់ហើយគេបញ្ជូនយើងទៅនៅតាមអង្គភាព ។

សុជា: កាលពីពូចេញទៅហ្នឹង ពូមានអាយុប៉ុន្មានដែរ ពូនិយាយម៉ិញ?

ម៉េត: ជាង១០ឆ្នាំ ។

សុជា: តែម្ដាយពូឃាត់មិនឲ្យពូទៅទេ?

ម៉េត: បាទ! ខ្ញុំក៏ថាចិត្តខ្លួនឯង ក៏ថាមិនដឹងទៅម៉េចដែរ ពួសូរតែគ្រាប់កាំភ្លើងពីរបីដើមៗ កាលហ្នឹងនៅតូចៗមានទៅនេះអី ហេតុអីតែគេបង្ខំកាលហ្នឹង ។ ហើយយើងទៅណោះ ជួនកាលឃើញគ្រាប់គេបាញ់ដូចព្យុះអញ្ចឹង យើងមិនរត់មកវិញ ហើយទៅគេតាមចាប់ ។ គេណោះគេអត់តាមទេ ប៉ុនណោះគេចាប់ ប្រធានភូមិ ។

សុជា: ប្រធានភូមិគេចាប់?

ម៉េត: បាទ! គេចាប់មក គេយកទៅដាក់នៅមន្ទីរ១៣អញ្ចឹងទៅ ។

សុជា: មន្ទីរ១៣ នៅឯណាទៅ?

ម៉េត: នៅកើតណោះ នៅកំពង់កុងណោះ ។

សុជា: កំពង់កុងអ្ហែះ?

ម៉េត: បាទ! ហើយគេណោះ គេមកដោះយកទៅវិញទៅ ។ ដល់ហើយគេឲ្យយើងវែកបាយស្អកអីអញ្ចឹងទៅ ។ ដល់ពេលចេញ ខ្ញុំវាចេះតែធំបន្តិចម្ដងៗ គេឲ្យទៅសមរភូមិទៅ ។ ហើយដល់ឆ្នាំ៧៥ ដែលពួកគេ ខ្មែរក្រហមគេមិនរំដោះទីក្រុងភ្នំពេញ ខ្ញុំចូលទៅដល់ក្រុងភ្នំពេញហ្នឹង ក៏ទទួលកម្មាភិបាលគេធំៗ គេចាប់ផ្ដើមរើសអង្គភាពនិរសារហ្នឹង ។

សុជា: បាទ!

ម៉េត: ដល់រើសទៅ គេឲ្យទៅហាត់រៀននៅសាលាបច្ចេកទេសទឹកខ្មៅហ្នឹង ។ រៀនសាលាបច្ចេកទេសចប់គេចាប់ផ្ដើមឲ្យយើងហ្នឹងយាមតាមកន្លែងរោងចក្រ តាមអគ្គិសនីអីអញ្ចឹងទៅ ។ ហើយដល់ដំណាក់កាលឆ្នាំ៧៦, ៧៧ គេឲ្យយើងទៅធ្វើការនៅគុកទួលស្លែងហ្នឹង ។ ហើយទៅមុនដំបូងហ្នឹងអត់ទាន់ដឹងថាខ្លួនឯងហ្នឹងយ៉ាងម៉េចទេ ។ ទៅដល់ភ្លាម គ្រាន់តែគេដាក់ឡានយើងចុះពីអាឡង់រ៉ឺវែហ្នឹង កាន់តែឃើញសុទ្ធតែឃើញ..................... ។ ហើយទៅចេះតែបារម្ភខ្លួនឯងថាគេយកមកដាក់នៅកន្លែងហ្នឹងដែរឬយ៉ាងម៉េច ឬមួយក៏មានតាមខ្សែរយៈបងៗដែលគេចាប់មកមុន

នោះមិនដឹង ដល់ហើយចូលដល់ក្នុងគុក គេឲ្យយើងចាប់រៀនសូត្រពីការហាត់ ការរៀន ការពារខ្លួនអីអញ្ចឹងទៅណាស់ ។

សុជាៈ កាលនោះពីណាគេបង្រៀន?

ម៉េតៈ ហ៊ីរ

សុជាៈ ហ៊ីរ ហ្នឹងគាត់មានឋានៈអីនៅទួលស្លែង?

ម៉េតៈ និយាយៗទៅ គាត់ជាអនុប្រធានគុកទួលស្លែង

សុជាៈ ចុះប្រធានគេឈ្មោះអីដែរ?

ម៉េតៈ ប្រធាន សៅ ឌុច ។

សុជាៈ សៅ ឌុច?

ម៉េតៈ បាទ!

សុជាៈ ចុះក្រោយមៅទៀត?

ម៉េតៈ ក្រោយមៅទៀត ដល់ដំណាក់កាលគេចាប់បងហ្នឹង គេដកដូចថា យើងអត់ដឹងទេ ដូចថាយើងនៅមានជាប់ប្រវត្តិរូបនយោបាយ ជាប់បងអីអញ្ចឹងទៅ យេិងវាមានការ វាលែងទុកចិត្តយើងហើយ ។ យើងមានការពាក់ព័ន្ធអញ្ចឹងគេដកយើងចេញទៅ ។ គេឲ្យយើងផ្លាកម៉ារយៈ ។ គេឲ្យយើងទៅធ្វើស្រូវធ្វើអីនៅព្រៃសរ ។ ហើយដល់ចុងបញ្ចប់ទួលយួនចូលរំដោះខ្មែរយើងនៅទីក្រុងភ្នំពេញ ។ ដល់បែកពីហ្នឹងទៅ បំរ៉ុងរត់មៅផ្ទះរត់មិនកើត ។ រត់ខ្លាចគេបាញ់យើងចោលទៀត ។ អញ្ចឹងចេះតែដើរតាមគេរហូតទៅលិចទៅ ដល់ភ្នំអីម៉េចទេ ភ្នំអីទេ ភ្លេចហើយ យូរ ។

សុជាៈ ខេត្តណាដែរ?

ម៉េតៈ ទៅតាមពោធិ៍សាត់ បាត់ដំបង ទៅរហូតទៅ ទៅតាមចុង តាមយែកទៅណាស់ ។

សុជាៈ បាទ!

ម៉េតៈ ហើយនៅឆ្នាំ៧៩ ជិតដាច់៧៩ហើយ ខ្ញុំវិលមៅផ្ទះវិញ ។ ដល់វិលមៅផ្ទះវិញ វៀតណាមក៏អត់មានសួរមានអីដែរ ។ ដល់ហើយខ្ញុំចូលមៅសារភាពនៅមុំ........នេះវិញ ដូចថាខ្ញុំចំណាំផ្លូវកាលហ្នឹងមានដែលចូលព្រៃចូលអី ចំណាំផ្លូវចូលមៅដល់លែកវិញ ជួបប្រធានភូមិនៅលែកហ្នឹង ហើយអត់ដឹងថាប្រធានភូមិទៀត ។ រួចក៏ខ្ញុំថា អឺៗ ចុះបើខ្ញុំចូលមៅសារភាពហ្នឹង តើវៀតណាមធ្វើបាប់ដែរអត់ ។ អ៊ឺ!អត់ទេក្មួយ ហើយចុះក្មួយឯងធ្វើអី ។ ហើយខ្ញុំកាលនោះធម្មតា ចេញមៅពីណោះមិនភូតភរខ្លាចគេសម្លាប់ ។ ខ្ញុំថាខ្ញុំនៅកងចល័តធ្វើស្រែធ្វើអីអញ្ចឹងទៅណាស់!

សុជាៈ  បាទ!

ម៉េតៈ  គេថា ចូលទៅអត់អីទេ ។ គ្រាន់តែចូលទៅដល់ ជំនាញការរៀតណាមគេមៅសម្ភាសន៍តាមហ្នឹង ខ្ញុំក៏រាយការណ៍តាមហ្នឹងទៅ បែកអង្ករ បែកស្បៀង បែកអីឲ្យយើង ធ្វើសំបុត្រឲ្យមៅផ្ទះ ។

សុជាៈ  មៅផ្ទះ?

ម៉េតៈ  បាទ! មៅរហូតដល់ផ្ទះ មៅដល់ឆ្នាំ៨០យើងនេះ ដើមឆ្នាំ៨០ ហើយក៏រកប្រពន្ធរកកូនអីអញ្ចឹងទៅ ។ បានមៅដល់សព្វថ្ងៃហ្នឹងទៅ ។

សុជាៈ  ហើយពូ ខ្ញុំសូមសួរបកទៅពីដើមវិញពូណា?

ម៉េតៈ  បាទ!

សុជាៈ  ពេលដែលពូចូលទព័ ចូលនៅភូមិកាលហ្នឹងអ្ហេះ?

ម៉េតៈ  បាទ!

សុជាៈ  ចូលធ្វើស្អីកាលហ្នឹង?

ម៉េតៈ  គ្មានធ្វើអីទេ ធ្វើតែស្រូវធ្វើអីអាដែលៗដូចតែនេះដែរ គ្រាន់តែអាហ្នឹងជានយោបាយរបស់គេ គេគ្រាន់តែទុកយើង កុំឲ្យយើងហ្នឹងភិតភ័យខ្លាំងទៅណា ដូចថាធ្វើនយោបាយតាមដំណាក់ៗអញ្ចឹងទៅណា ។

សុជាៈ  បាទ!

ម៉េតៈ  ហើយកាលនោះ យើងវានៅតូចគ្មានទាន់ដឹងថាធ្វើ រៀនសូត្រក៏មិនទាន់បានជ្រៅជ្រះ ថ្នាក់ទី ១២ ចាស់ហ្នឹងពីមុន ។

សុជាៈ  ហើយកាលពីពូចូលទៅភូមិហ្នឹង ម្ដាយពូក៏មិនចង់ឲ្យចូលដែរកាលហ្នឹងអ្ហេះ?

ម៉េតៈ  អត់ទេ អត់ឲ្យចូលទេ ។

សុជាៈ  ហើយមានគេមៅនិយាយថាម៉េច បានពូចូលទៅ?

ម៉េតៈ  គេមៅដល់ គេថាបើយើងមិនទៅសមរភូមិមុខទេ យើងនៅត្រឹមឃុំសិនទៅ នៅធ្វើការឃុំដូចជាធ្វើឈ្លបឃុំ ឈ្លបអីអញ្ចឹងទៅ ។ តាមការពិតទៅ ដូចថាមិនធ្វើឈ្លបគេ គេឲ្យយើងទៅដាំសណ្ដែកអីនៅចុងព្រែកទៅ ។ ដល់ពេលដំណាក់កាលដែលគេចាប់ផ្ដើមរើសទព័ គេចាប់ផ្ដើមដកយើង ។

សុជាៈ  អញ្ចឹងបានន័យថា យើងគ្រាន់តែត្រៀមទេ?

ម៉េតៈ  បាទ! ជាត្រៀមទេ

សុជាៈ  អញ្ចឹងកាលហ្នឹងមានគ្នាច្រើនទេ ដែលត្រៀមហ្នឹង?

ម៉េតៈ មានគ្នាប្អូនដប់នាក់ ម៉ាសារប្អូនដប់នាក ប្អូនប្រាំនាក់អញ្ចឹងទៅ។

សុជាៈ ហើយអាយុប្រហែលប៉ុន្មានដែរ?

ម៉េតៈ អាយុប្រហែលស្រករៗខ្ញុំ ក្មេងៗហ្នឹង។

សុជាៈ ប្រហែល ១៣, ១៤, ១៥ អញ្ចឹងទៅ?

ម៉េតៈ បាទ! ១៥, ១៦, ខ្លះ១៨អីអញ្ចឹងទៅ។

សុជាៈ ហើយអ្នកដែលបំរ៉ុនគាត្រៀមហ្នឹង គេសុទ្ធតែជាអ្នកនៅក្នុងភូមិហ្នឹងដែរ ឬអ្នកមកពីផ្សេងៗទៀត?

ម៉េតៈ ផ្សេងៗទាំងអស់ តាមឃុំផ្សេង តាមភូមិផ្សេងអញ្ចឹងទៅ មិនមែននៅក្នុងភូមិហ្នឹងតែមួយទេ។

សុជាៈ បាទ!

ម៉េតៈ ជួនកាលភូមិហ្នឹងមានពីរក៏មាន។

សុជាៈ កាលហ្នឹងនៅក្នុងឆ្នាំណាដែរ ដែលពូត្រៀមនៅឃុំ?

ម៉េតៈ នៅដើមឆ្នាំ៧៣ ចុងឆ្នាំ៧២។

សុជាៈ ហើយគេឲ្យនៅត្រៀមហ្នឹងប៉ុន្មានឆ្នាំទៅនៅឃុំហ្នឹង?

ម៉េតៈ អត់ដល់ឆ្នាំទេស៍ ប៉ុន្មានខែ បើគិតទៅប្រហែលជា៩ខែ ។ កាលហ្នឹងវាមានការភ្លេចភ្លាំង អត់បានទៅដឹងថ្ងៃខែអីទេ។

សុជាៈ ហើយពេលដែលធ្វើការនៅចុងព្រែកហ្នឹង ដំណាំដែលបានមកហ្នឹងគេយកទៅណាវិញ?

ម៉េតៈ មិនដឹងជាទៅខាងណាទេ ព្រោះអីគេយកទៅដាក់នៅក្នុងឃ្លាំងអីមួយ។

សុជាៈ ឃ្លាំងទេអាហ្នឹងអ្ហេះ?

ម៉េតៈ បាទ!

សុជាៈ មិនមែនយកទៅចែកឯកជនអីទេអ្ហេះ?

ម៉េតៈ បាទ! អត់ចែកទេ តាមឃ្លាំង ដូចថាអាហ្នឹងជារបស់ឃុំគេណាស៍ មិនមែនជារបស់ប្រជាជនទេ។

សុជាៈ អញ្ចឹងតាមលក្ខណៈដែលពូនិយាយមក ពេលហ្នឹងបានន័យថាឆ្នាំ៧៣ហ្នឹង នៅក្នុងស្រុកភូមិពូហ្នឹងការគ្រប់គ្រងហ្នឹងមិននៅក្នុងរបបលន់ណុលទេអ្ហេះ?

ម៉េតៈ ហ្នឹង មិនមែនទេ។

សុជាៈ របបអីដែរ?

ម៉េតៈ របប កាលហ្នឹងគេថា រណសិរ្ស។

សុជាៈ តាមយើងចំណាំគេហៅរបបអីដែរ?

ម៉េតៈ ក្រោយមៅ យើងនិយាយក្រោយមៅថា បើខ្មែរក្រហម ខ្ញុំមិនដែលឮថាខ្មែរក្រហមទេ។

សុជាៈ កាលហ្នឹងមិនទាន់ឮថាខ្មែរក្រហមទេ?

ម៉េតៈ នៅទេ។

សុជាៈ ឮថារណសិរ្ស?

ម៉េតៈ បាទ! គេហៅថាពួករំដោះណាស់។

សុជាៈ ពួករំដោះអ្ហេះ?

ម៉េតៈ បាទ! រំដោះគឺជាអ្នករំដោះ លន់ នល់ ឲ្យផុតពីការជិះជាន់ទៅណា។

សុជាៈ បាទ! ហើយកាលហ្នឹងស្លៀកពាក់អង្គការគេ គេហៅជាអង្គការ គេហៅថ្នាក់លើ ឬគេហៅជាម៉េច?

ម៉េតៈ ស្លៀកពាក់ហ្នឹងគឺថា មានថ្នាក់លើផ្សេងទៅ មានខោអាវយុទ្ធជនផ្សេងទៅណា វាខុសៗគ្នាដែរទេ ប៉ុនខោអាវ តែខ្មៅទេ អត់មានពណ៌ដូចយើងសព្វថ្ងៃអីអត់ទេ។ មានស្គាល់ដែរដូចថាឋានៈគេមេកង វរសេនាតូច វរសេនាធំអីអញ្ចឹងទៅណាស់។

សុជាៈ ហើយកាលហ្នឹងនៅតាមភូមិឃុំអីគេបាយរួមទេ?

ម៉េតៈ កាលហ្នឹង កាលខ្ញុំចូលបាយឯកជនទេ។

សុជាៈ បាយឯកជនទេ!

ម៉េតៈ បាទ! ប៉ុនការងាររួម

សុជាៈ ដីស្រែអីហ្នឹងដាក់ជាដីរួមហើយអ្ហេះ?

ម៉េតៈ បាទ! គ្រាន់ដាំបាយតាមផ្ទះ។

សុជាៈ ចែកជារបបអ្ហេះ?

ម៉េតៈ បាទ! ចែកជារបប។

សុជាៈ កាលហ្នឹង ប្រធានភូមិពូឈ្មោះអីដែរ?

ម៉េតៈ ឈ្មោះ យឹម។

សុជាៈ ឈ្មោះ យឹម អ្ហេះ?

ម៉េតៈ បាទ!

សុជាៈ គាត់អ្នកភូមិហ្នឹងដែរឬអ្នកមៅពីឆ្ងាយ?

ម៉េតៈ អ្នកភូមិហ្នឹង។ នៅភូមិហ្នឹងហ្នង។

សុជាៈ ចុះប្រធានឃុំ?

ម៉េតៈ ខ្ញុំភ្លេចហើយ ពូ សូរ ផួន ណាមិនដឹងទេ ប៉ុនថាពួកហ្នឹងស្លាប់អស់ហើយ ។

សុជាៈ បាទ! ចុះពូចូលទ័ពហ្នឹងប្រធានក្រុម ប្រធានអីហ្នឹងឈ្មោះអីដែរ?

ម៉េតៈ ក្នុងឃុំហ្នឹង?

សុជាៈ បាទ!

ម៉េតៈ ភ្លេចហើយ ។

សុជាៈ ចុះអ្នកដែលទៅនិយាយឲ្យថា ឈ្មោះអីដែរ?

ម៉េតៈ អ្នកទៅនិយាយប្រធានភូមិហ្នឹង បងឃឹម ហ្នឹង ។ គេអ្នកធ្វើនយោបាយ ឃឹម ក៏មិនមែនអ្នកឆ្ងាយពីឪពុកម្ដាយដែរទេ ។ ដូចថាជាប់ខ្សែអីពីចាស់ ពីនេះមៅ ។

សុជាៈ ជាសាច់ញាតិ?

ម៉េតៈ បាទ! ជាសាច់ញាតិអី ដូចជិតខាង ហើយគេចេះតែមៅធ្វើនយោបាយថា ធំឯងឲ្យកូនចូលទ័ពមួយទៅ ។ ហើយម្ដាយខ្ញុំចេះថា កូនចូលទ័ពម៉េចទៀត បើអាបងនោះទៅបាត់ហើយ ។

សុជាៈ អូរអញ្ចឹង បងពូដែលស្លាប់ហ្នឹងចូលមុនពូ?

ម៉េតៈ ចូលមុនៗ វាចូលតាំងពីឆ្នាំ៧០ បើនិយាយចុងឆ្នាំ៧២ ដើមឆ្នាំ៧១ ។ ចូលមុនខ្ញុំប៉ុន្មានឆ្នាំ ដល់ហើយបានគេមៅធ្វើនយោបាយជាមួយម្ដាយខ្ញុំហ្នឹង ឲ្យខ្ញុំចូលមួយទៀត ។

សុជាៈ ដល់ពេលបងពូចូល ចូលនៅណាដែ?

ម៉េតៈ ចូល ចូលនៅស្រុកហ្នង ។

សុជាៈ ទ័ពស្រុកហ្នងអេ្ហះ?

ម៉េតៈ បាទ! ទ័ពស្រុកហ្នង ។ ដល់ចេញពីស្រុកទៅតំបន់ តំបន់ទៅភាគទៀត ។

សុជាៈ ហើយពីណាអ្នកយកបងពូទៅដែរកាលហ្នឹង?

ម៉េតៈ ទេ កាលហ្នឹងខ្ញុំវាមិនដឹងជានរណា អត់ទាន់ ខ្ញុំកាលហ្នឹង យើងកាលហ្នឹងនៅមានពួក.......ហើយខ្ញុំនៅវត្តទៅ ។ ដលគាត់ខ្ញុំចេញទៅបាត់ប៉ុន្មានពីរឆ្នាំ ជាងម៉ាឆ្នាំទេ បានខ្ញុំចេញពីវត្តមៅ ។

សុជាៈ ចុះហេតុអីបានជាពូចេញពីវត្តមៅ?

ម៉េតៈ ចុះកាលហ្នឹងគេបិទវត្តអារ៉ាមនោះ ។

សុជាៈ អូរ! នៅក្នុងឆ្នាំ៧៣ វត្តអារ៉ាមអីក៏គេបិទដែរ?

ម៉េតៈ បាទ!

សុជាៈ គេលែងឲ្យមានលោកសង្ឃអីហើយ?

ម៉េតៈ បាទ! លែងឲ្យមានហើយ ។

សុជាៈ ចុះវត្តអារ៉ាមអីគេមានវៃអីនៅ?

ម៉េតៈ នៅទេ ។

សុជាៈ ចុះលោកសង្ឃគេឲ្យផ្សឹក ឬក៏គេផ្សឹកលោកហ្មង?

ម៉េតៈ គេផ្សឹកលោកហ្មង ។

សុជាៈ មានដឹងថាគេផ្សឹកលោកម៉េចទេ ពូនៅវត្តហ្នឹង?

ម៉េតៈ អត់ដឹង ។ ព្រោះខ្ញុំចេញទៅបាត់ ។

សុជាៈ ចុះពេលដែលពូនៅភូមិនៅឃុំ ក្រោយមៅគេយកពូទៅណាទៀត?

ម៉េតៈ ភូមិឃុំអ្ហេះ?

សុជាៈ បាទ!

ម៉េតៈ គេយកខ្ញុំទៅស្រុក ។

សុជាៈ ស្រុក ។

ម៉េតៈ កាលហ្នឹងគេហៅស្រុក១៨ ។

សុជាៈ នៅខាងណាវិញទៅ?

ម៉េតៈ នៅក្រោមនេះ ពីមុនគេហៅស្រុកកោះធំ ប៉ុនឥឡូវស្រុកកោះធំ ពីមុនគេហៅស្រុក១៨ ។

សុជាៈ គេដាក់ឈ្មោះស្រុកជាលេខហ្នឹងតាំងពីឆ្នាំណា ជំនាន់ណាដែរ?

ម៉េតៈ អ្ហេ! ស្រុក១៨ តាំងពីឆ្នាំ៧០មៅណោះ អ្ហេ៧១ ។ ប៉ុនខ្ញុំកាលណោះមិនទាន់ដឹងថាគេធ្វើទព័ ធ្វើយោធាអីម៉េច អត់ដឹងដែរ ។ ប៉ុនដល់ចូលខ្លួនឯង ឮគេដាក់ថាស្រុក១៨ ។

សុជាៈ ចូលនៅកន្លែងណាដែរ ចូលទៅស្រុកកន្លែងណា?

ម៉េតៈ ចូលទៅស្រុកហ្នឹងអ្ហេះ?

សុជាៈ បាទ!

ម៉េតៈ ចូលទៅស្រុក មិនមែននៅកោះធំនេះទេ នៅក្រោមនោះវិញទេ ។

សុជាៈ នៅក្រោមណោះវិញ?

ម៉េតៈ បាទ!

សុជាៈ នៅតាមព្រែចម្ការទេ?

ម៉េតៈ បាទ! តាមភូមិយើងណោះវិញទេ ។

សុជាៈ តែនៅទីរួមស្រុកកោះធំយើងនេះ កាលហ្នឹង?

ម៉េតៈ កាលហ្នឹងនៅជាកន្លែងផ្លូវខ្មោចទេកាលហ្នឹង ទព័យុទ្ធជន ។

សុជាៈ ចុះ៧៣ហ្នឹង លែងមានលន់ នល់ នៅកោះធំហ្នឹងហើយ?

ម៉េតៈ អត់មានទេ ។

សុជាៈ ចេញអស់ហ្នង?

ម៉េតៈ បាទ!

សុជាៈ លន់ណុល ចេញពីស្រុកកោះធំហ្នឹងតាំងពីឆ្នាំណាដែរ ទព័លន់ណុលហ្នឹង?

ម៉េតៈ ទេ! អត់ដឹងទេ កាលហ្នឹង ។

សុជាៈ ចុះខ្មែរក្រហមដែលចលនាអន្តការរំដោះហ្នឹង ទព័រំដោះហ្នឹងមាននៅក្នុងភូមិនេះតាំងពីឆ្នាំណាមៅ ដែរ?

ម៉េតៈ ទព័រំដោះនេះ បើតាមខ្ញុំដឹងមៅកាលហ្នឹងមានដូចជា យៀកកុង ឬមៅពីក្រោមហ្នឹងឡូកឡំគ្នាហ្នឹង ជាមួយយៀកណាមហ្នឹង ដល់យូរទៅបែកពីយៀកណាមហ្នឹងបានចាប់ផ្តើមខ្មែរផ្សេងៗវិញទៅ ហើយយួនវាទៅក្រោមវិញអស់ទៅ ។

សុជាៈ ហើយកាលហ្នងលែងមានទាហានលន់ណុល ទាហានបាំរ៉ាអីហើយនៅកោះធំនេះ?

ម៉េតៈ លែងហើយ អត់មានទេ

សុជាៈ ចុះពូចូលនៅស្រុកកោះធំ នៅភូមិអីគេដែរហ្នុង?

ម៉េតៈ ភូមិហ្នឹង?

សុជាៈ បាទ!

ម៉េតៈ ចូលនៅស្រុកហ្នឹង បើនិយាយអត់ដឹងភូមិណាៗ ។

សុជាៈ ចុះឃុំអីដែរ?

ម៉េតៈ ឃុំ កាលហ្នឹងឃុំសំពៅពូន ។

សុជាៈ នៅត្រើយខាងណោះ ឬខាងហ្នឹង?

ម៉េតៈ នៅខាងណោះ ។

សុជាៈ ត្រើយខាងណោះអ្ហេះ?

ម៉េតៈ បាទ! ត្រើយខាងណោះក៏មាន ត្រើយខាងណេះក៏មានទព័ដាក់គ្រប់កន្លែង ។

សុជាៈ ចុះពូចូលនៅត្រើយខាងណា?

ម៉េតៈ ខ្ញុំចូលនៅត្រើយខាងណោះហើយ ។

សុជាៈ ទៅកើតហើយអ្ហេះ?

ម៉េតៈ បាទ! នៅខាងជើងខ្ពប ។

សុជាៈ កាលហ្នឹងចូលទៅ អ្នកដែលត្រៀមជាមួយពូហ្នឹង ទៅទាំងអស់គ្នា ឬក៏?

ម៉េតៈ ទៅ មិនអាចទៅទាំងអស់ទេ ជួនកាលគេអ្នកខាងលើមៅ គេត្រូវការប៉ុន្មាន ឧបមាថាប៉ុន្មាន មាកងអញ្ចឹងទៅ ។

សុជាៈ មាកងមានគ្នាប៉ុន្មាននាក់?

ម៉េតៈ មាកងហាមានមាវរសេនាតូចវាមានប៉ុន្មានទេ ដូចជាង៣០នាក់ ទៅអញ្ចឹងទៅបានប្រហែលប៉ុន្មានខែអីទៀតទៅ គេនៅខ្វះ ដូចថាវាមានបញ្ហាទ័ពវាអស់ទៅ វាមានអាខ្វះផាប់វាអីអញ្ចឹងទៅណាស់ បានគេចាប់ផ្តើមយកទៅទៀតទៅ ។

សុជាៈ ហើយកាលហ្នឹង កន្លែងដែលពូចូលមានប្រធានឈ្មោះអីគេទៅ?

ម៉េតៈ កន្លែងដែលខ្ញុំចូលអ្ហេះ?

សុជាៈ បាទ!

ម៉េតៈ ប្រធាន កាលហ្នឹងមាន ព្រីង មាន គាល់ អញ្ចឹងទៅ ស្លាប់អស់ហើយពួកហ្នឹង ។

សុជាៈ អាហ្នឹងគេហៅកងពលលេខប៉ុន្មាន?

ម៉េតៈ បើនិយាយទៅនៅកងទ័ពស្រុក១៨ វា ។

សុជាៈ នៅកងទ័ពស្រុកទេ អត់ទាន់ទ័ពកងពលទេអ្ហេះ?

ម៉េតៈ នៅទេ ។ ទាល់តែចេញពិស្រុកហ្នឹងទៅ បានទៅដល់ភូមិភាគ ទ័ព ហ្នឹងនៅទន្លេមេគង្គ ។

សុជាៈ ហ្នឹងគេហៅភូមិភាគអីដែរ?

ម៉េតៈ ភូមិភាគ នរតី ។

សុជាៈ កាលហ្នឹងពូចូលទៅភូមិភាគនិរតីហើយណោះ?

ម៉េតៈ បាទ! កងពលលេខ១២ ។

សុជាៈ កងពលលេខ១២ ។ ចុះកងវរសេនាធំលេខប៉ុន្មានដែរ?

ម៉េតៈ កងវរសេនាធំ២៧០ ។

សុជាៈ ២៧០ ។ ចុះវរសេនាតូច?

ម៉េតៈ វរសេនាតូច២៧៥ ។ គេប្រកាសចេញពីស្រុកហ្នឹងទៅហ្នង ។

សុជាៈ បាទ! ពីណាគេអ្នកមៅប្រកាសហ្នឹង?

ម៉េតៈ អ្នកមៅប្រកាសបើនិយាយទៅ តាណាត ។

សុជាៈ តាណាត ហើយគាត់ប្រធានអីដែរ?

ម៉េតៈ គាត់ប្រធានកងពល

សុជាៈ កងពលលេខប៉ុន្មាន?

ម៉េតៈ កងពលលេខ១២

សុជាៈ ចុះកាលហ្នឹងកងពល៧០៣នោះ?

ម៉េតៈ ៧០៣ ទើបប្រកាសយើងអាដេងឆ្នាំ៧០ប៉ុន្មាន ៧៦, ៧៧ នេះតើ ។

សុជាៈ ពេលដែលជ័យជំនះនេះទេ?

ម៉េតៈ បាទ! កាលពីមុនកងពល១២ទេ ។

សុជាៈ ១២ ទេ!

ម៉េតៈ កាលនៅធ្វើសង្គ្រាមជាមួយលន់ នល់ ណាស់ ។

សុជាៈ អូរ! កងពល១២ ។ តែចូលទៅមិនមែនមូលដ្ឋានហ្នឹងចេញពីនេះទៅខាងត្រង់ឡើងស្ពានទឹកខ្មៅទេ?

ម៉េតៈ មិនមែនទេ ចេញខាងទន្លេមេគង្គអញ្ចឹងវិញ ។

សុជាៈ ទៅតាមអ្នកលឿងវិញ?

ម៉េតៈ បាទ! អត់ដល់អ្នកលឿងទេ ទៅតាមយើងទួលក្រសាំង ខាងព្រែកតូចអីវិញ ទៅវ៉ៃគ្នាយើងជិតខេត្តតាខ្មៅហ្នឹង ។ វាមានតាមផ្នែកគ្នា ។ ខាងនិរតីគេទៅចំហៀងខាងលិចតាកែវទៅ ខាងបូព៌ាៗទៅ ខាងនិរតីៗទៅ ។

សុជាៈ បាទ! អញ្ចឹងបានន័យថាកងពល១២ ពូដែលក្រោមចំណុះរបស់តាណាតហ្នឹង ក្រោយមៅក្លាយជាកងពល៧០៣ ទទួលបន្ទុកកោះធំ ស្អាង មុខព្រួញហ្នឹង ។

ម៉េតៈ បាទ!

សុជាៈ ចូលទៅភ្នំពេញ?

ម៉េតៈ បាទ!

សុជាៈ ចុះពូមានដែលឡើងទៅកៀនស្វាយទេ?

ម៉េតៈ អត់ទេ ។

សុជាៈ អញ្ចឹងកងពលគេផ្សេងទៀត?

ម៉េតៈ បាទ!

សុជាៈ ពូមានដឹងថាខាងណុងផ្នែកអីដែរ?

ម៉េតៈ អត់ដឹង ។

សុជាៈ ពូចុះនេះភូមិភាគអីដែរ ភូមិភាគបូព៌ា?

ម៉ែតៈ និរតី ។ ខាងកេណោះ ខាងបូព៌ា

សុជាៈ ខាងណោះខាងនិរតី?

ម៉ែតៈ បាទ!

សុជាៈ ចុះកាលហ្នឹង មានដឹងថាប្រធានភូមិភាគនិរតី នរណាគេដែរ?

ម៉ែតៈ និរតី ខ្ញុំអត់ដឹងដែរខ្ញុំ ។

សុជាៈ តែបើតាណាត ហ្នឹងកងពល?

ម៉ែតៈ បាទ! កងទ័ព កងពល ។

សុជាៈ ហើយដល់ពេលពូនៅខាងណោះហើយ ចូលកងពល កងទ័ព១២នេះ ហើយក្រោយមៅទៅណាទៀតដែរ?

ម៉ែតៈ តាណាត អ្ហេះ?

សុជាៈ បាទ!

ម៉ែតៈ គាត់ចេញពីកងពល១២ គាត់ទៅសេនាធិការនៅភ្នំពេញ ។

សុជាៈ ចុះនិយាយពីពូវិញ?

ម៉ែតៈ ខ្ញុំអ្ហេះ?

សុជាៈ បាទ!

ម៉ែតៈ ចេញពីកងពល១២ ខ្ញុំនៅក្នុងកងពល៧០៣ដដែលហ្នឹង ។

សុជាៈ តែដល់ពេលវៃចូលភ្នំពេញ ពូនៅមុខព្រួញណាដែរ?

ម៉ែតៈ ខ្ញុំនៅម្តុំ ដួនកាលនៅតាខ្មៅ ចក្រអង្រែយើងនេះ ដួនកាលឡើងទៅដល់ក្បាលថ្នល់ ។

សុជាៈ ខ្ញុំនិយាយម៉ាសារទៀត មុនដែលពូចូលទ័ពហ្នឹង ក្រោយដែលពូចូលទ័ពមៅ គេឲ្យធ្វើអីខ្លះទៀត? ចូលទ័ពនៅសំពៅពូនណោះ ទ័ពស្រុក?

ម៉ែតៈ កាលហ្នឹងគេឲ្យខ្ញុំធ្វើ បើនិយាយរួមមុនដំបូងគេឲ្យខ្ញុំរែកបាយ ដល់អស់ពីរែកបាយ មុនដំបូងគេធ្វើនយោបាយយើងមុនដំបូងគេមិនទាន់បង្ហឹយើងទេណា ។ ឲ្យយើងរែកបាយ ឲ្យយើងធ្វើសេដ្ឋកិច្ចអីដឹកជញ្ជូនទៅទ័ពមុខនោះណា ដល់ពេលដែល ដូចថាយើងវាមានការលែងភ័យលែងភិតអីហើយគេឲ្យយើងចូលធ្វើនិរសារ ។

សុជាៈ និរសារ?

ម៉ែតៈ បាទ! និរសារវរសេនាតូច វរសេនាធំអញ្ចឹងទៅ ។

សុជាៈ កាលហ្នុងនិរសារឲ្យខាងណា ឲ្យឈ្មោះអីដែរ?

ម៉ែតៈ និរសារកាលហ្នឹង ច្រើនកម្មាភិបាលណាស់ ជួនណាកម្មាភិបាលដូចប្រគល់ឲ្យទៅ បងហៀង អញ្ចឹងទៅ ។ ដល់អស់ ហៀង ទៅទៅ ឆ្ងួញ អញ្ចឹងទៅ ។ ដល់អស់ ឆ្ងួញ ទៅ ហាក់ អញ្ចឹង ទៅ ។

សុជាៈ តែថ្នាក់អីគេ ពួកគាត់?

ម៉ែតៈ គាត់ត្រឹមនាទី មុនដំបូងអនុសេនាធំអញ្ចឹងទៅ ហើយវរសេនាតូច វរសេនាធំអញ្ចឹងទៅ ។

សុជាៈ ហើយតួនាទីនិរសារ ហ្នឹងធ្វើអីគេទៅ?

ម៉ែតៈ និរសារហ្នឹង គ្រាន់តែរត់នាយអាយ ដូចថាការពារគេអ្នកធំអញ្ចឹងទៅណា មិនអាចដូចយើងនៅធ្វើព័ទេ ។ អានេះដូចគេប្រើឲ្យទៅប្រាប់កន្លែងអ្នកដាំបាយអញ្ចឹងទៅ រួចប្រាប់ទៅខាងមុខទៅឲ្យគេដកខ្សែត្រៀមចេញវិញទៅអាហ្នឹងណាស់ ។

សុជាៈ ហើយពូរត់បាយស្មុកហ្នឹងបានប៉ុន្មានខែដែរ?

ម៉ែតៈ ខ្ញុំរត់ហ្នឹងវាអត់ទៀងដែរ បើនិយាយក្នុងឆ្នាំអត់មានដល់ឆ្នាំទេ នៅក្នុងខែទេ ។

សុជាៈ បានម៉ាខែពីរខែទេ?

ម៉ែតៈ បានពីរបីខែ ។

សុជាៈ ដល់ពេលរត់បាយស្មុកហើយ បានចូលនិរសារ?

ម៉ែតៈ បាទ!

សុជាៈ និរសារហ្នឹង ច្រើនធ្វើការនៅក្នុងដីកោះធំនេះ ឬនៅខាងត្រើយខាងណោះ?

ម៉ែតៈ នៅត្រើយខាងណោះ នៅក្នុងស្រុកកោះធំដដែល ។

សុជាៈ បានប៉ុន្មានខែដែរ?

ម៉ែតៈ បើគិតនិរសារ ខ្ញុំធ្វើរហូត ធ្វើទាល់តែដល់បែកភ្នំពេញ ។

សុជាៈ ប៉ុលពត ចូលទីក្រុងភ្នំពេញហ្នឹង?

ម៉ែតៈ បាទ!

សុជាៈ ចុះពូមានបានចូលទ័ពឡើងសមរភូមិគេដែរ?

ម៉ែតៈ ចូល ចេះតែចូលជាមួយកម្មាភិបាលគេទៅ ។ យើងដូចថាអង្គរក្សទៅណា ដូចជានិរសារគេអញ្ចឹង ។

សុជាៈ ហើយមានកាន់កាំភ្លើងទេនិរសារហ្នឹង?

ម៉ែតៈ កាន់ បើមិនកាន់ដែរ រត់ការពារម៉េចកើត ។ ទៅស្អែកៗឲ្យគេបាញ់ទៅ ។

សុជាៈ ហើយដល់ពេលទៅដល់ភ្នំពេញ និរសារ ជិតវៃចូលភ្នំពេញហ្នឹងឲ្យនិរសារឲ្យពីណាគេកាលហ្នឹង?

ម៉េត: កាលហ្នឹងនិរសារឲ្យ បងឈុន ។

សុជា: ឈុន ហ្នឹងគាត់មានតំណែងអីដែរ?

ម៉េត: ឈុន ហ្នឹងគាត់វរសេនាធំ ។

សុជា: វរសេនាធំ?

ម៉េត: បាទ!

សុជា: រាងរៅគាត់យ៉ាងម៉េចដែរ?

ម៉េត: គាត់រាងខ្ពស់ស្តើង ។

សុជា: សរ ឬខ្មៅ?

**ផ្នែក «១»**

សុជា: ចុះពេលដែលវៃចូលទីក្រុងភ្នំពេញ ពូមានបានទៅជួបជាមួយគេដែរ?

ម៉េត: ដូចអត់មានបានជួបទេ ព្រោះទ័ពគេទៅមុនអស់ហើយ ។

សុជា: ទ័ពពិសេសគេទៅមុនហើយ?

ម៉េត: បាទ!

សុជា: តែពួកនិរសារទៅតាមក្រោយ?

ម៉េត: ទៅតាមក្រោយ ទៅតាមកម្មាភិបាល ។ កងពិសេសគេចូលទៅវៃគ្នាមុខអស់ហើយ ស្ងាត់អស់ហើយ បានយើងចូលទៅតាមក្រោយគេហ្នឹង ។

សុជា: កាលហ្នឹងពូឈរនៅណា?

ម៉េត: អត់ទៀងទេ ពេលវៃចូលរំដោះទីក្រុងភ្នំពេញនេះ គឺជាអត់ទៀងទេ រកកន្លែងកំណត់អត់ឃើញ ជួនកាលគេផ្លាស់ឲ្យយើងនៅត្រឹមចាក់អង្រែអញ្ចឹងទៅ ជួនណាគេផ្លាស់ឲ្យយើងទៅនៅកន្លែងពេទ្យចិនអញ្ចឹងទៅ ជួនកាលគេឲ្យយើងបកទៅនៅមាត់ទន្លេនោះវិញទៅ ។

សុជា: ការទៅនៅហ្នឹងបានប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ?

ម៉េត: ទៅនៅអត់បានដល់ខែទេ ចុះកាលហ្នឹងភ្លាមៗ គេរូតរះ ដកកម្លាំងទៅការពារគ្រប់កន្លែងទៅណា

សុជា: ចុះកាលហ្នឹងនៅក្នុងក្រុងភ្នំពេញហ្នឹង មុន៧៥ពេលដែលវៃចូលមៅ មិនមានវៃពីតំបន់ផ្សេងៗ?

ម៉េត: បាទ!

សុជា: ទ័ពបូព៌ា ទ័ពឧត្តរ ទ័ពនិរតី ទ័ពពិសេស?

ម៉េត: បាទ! វៃផ្ទប់គ្នាទាំងអស់ ។

សុជាៈ  វែដ្ឋប់គ្នាហ្នឹងដល់ពេល  ចូលម៉ៅដល់ទីក្រុងភ្នំពេញ  គេមានចែកប្លុកគ្នា  មានអាកងពលមួយៗដែរ

ម៉េតៈ  បាទ!

សុជាៈ  ចុះកងពលពូនៅខាងណាទីក្រុងភ្នំពេញដែរ?

ម៉េតៈ  ខ្ញុំខាងជាយក្រុងភ្នំពេញ  ប៉ុន្តែប៉ែកខាងត្បូង  ខាងខេត្តតាខ្មៅយើងនេះ។

សុជាៈ  ខាងតាខ្មៅ-ចាក់អង្រែ។  អញ្ចឹងពូមិនអាចដើរទៅខាង?

ម៉េតៈ  ទៅខាងបូព៌ាអត់ទេ  ខ្វាចប្រទាំគ្នា។

សុជាៈ  បូព៌ានៅឯណាដែរ?

ម៉េតៈ  បូព៌ានៅផ្នែកខាងកើត  នៅច្បារអំពៅ  ក្បាលថ្នល់យើងហ្នឹងណា។

សុជាៈ  ចុះខាងពួកឧត្តរ?

ម៉េតៈ  ខ្ញុំអត់ដឹង។

សុជាៈ  ចុះខាងណោះ  ខាងជ្រោយចង្វារអី  អាហ្នឹងគ្រប់គ្រងខាងណាដែរ?

ម៉េតៈ  ខាងជ្រោយចង្វារ  ខ្ញុំអត់ដឹងដែរ  មិនដឹងគ្រប់គ្រងដោយពួកណាដែរ។

សុជាៈ  ចុះខាងទួលគោក?

ម៉េតៈ  ទួលគោក  ក៏មិនទាន់ដឹងដែរ  ព្រោះអីចូលទៅនេះមិនទាន់ដឹង  អត់ស្គាល់។

សុជាៈ  យេិងនៅតែកន្លែងយើងហ្នឹង?

ម៉េតៈ  បាទ!  នៅតែកន្លែងយើង  អត់ដែលស្គាល់ថា  កន្លែងណាកងពលណា  កន្លែងណាកងពលណាទេ

សុជាៈ  ចុះគេមេអត់ដែលប្រាប់ថាមិនឲ្យដើរទៅណោះទៅណោះទេ?

ម៉េតៈ  អត់ទេ!  ហ៊ានៈយើងអត់ដើរដូចគេអ្នកធំទេ។

សុជាៈ  ហើយកាលហ្នឹង  ពួកទព័ពូខាងនិរតីនេះស្លៀកពាក់យ៉ាងម៉េចដែរ?

ម៉េតៈ  ខ្មៅ

សុជាៈ  ចុះខាងបូព៌ា?

ម៉េតៈ  បូព៌ា  ដូចទាហាន។

សុជាៈ  ពណ៌យ៉ាងម៉េច?

ម៉េតៈ  ពណ៌ទាហាន  ដូចអាវខ្ញុំពាក់នេះ។

សុជាៈ  ពណ៌អាចម៍ហ្នឹង។

ម៉េតៈ  បាទ!

សុជាៈ  បន្ទាប់ពីពូបានឈរជើងនៅទីក្រុងភ្នំពេញហើយ  បន្ទាប់ម៉ៅបានគេឲ្យធ្វើអីទៀតដែរ?

ម៉េតៈ បន្ទាប់មៅបានគេដកខ្ញុំមៅ ។ ដកឲ្យមៅរៀន ។

សុជាៈ នៅពេលដែលទៅឈរជើងម្តងនៅនេះម្តងនៅនោះហ្នឹង គេឲ្យទៅធ្វើអីដែរ?

ម៉េតៈ អត់មានធ្វើអីទេ អាហ្នឹងនៅយាមកាមការពារខ្សែក្រវ៉ាត់ទីក្រុងហ្នឹង ហើយដល់ពេលយើងនៅឈរជើងហ្នឹងហើយ ដល់ពេលគេជំណាក់កាលគេត្រូវដកនិរសារយកមកឲ្យរៀនសូត្រ គេដកម្នាក់ ។

សុជាៈ មៅក្រុម?

ម៉េតៈ បើនិយាយទៅថាកម្មាភិបាលមួយដកមួយៗ តាមនិរសារអញ្ចឹងណា ។

សុជាៈ កាលហ្នឹងពូធ្វើឲ្យ ឈុន ហ្នឹងអ្ហេះ?

ម៉េតៈ បាទ!

សុជាៈ ចុះមៅក្រុមពូមានគ្នាប៉ុន្មាននាក់ដែរ?

ម៉េតៈ កងនិរសារវាមាន៥០នាក់ ។

សុជាៈ ហ្នឹងនិរសារ ឈុន ហ្នឹង?

ម៉េតៈ អត់ទេ! និរសារគ្រប់ មៅកងពលហ្នឹងហ្នង ។

សុជាៈ ពូនិរសារប្រចាំឲ្យឈុន ហ្នឹង មានគ្នាប៉ុន្មាននាក់ដែរ?

ម៉េតៈ កាលហ្នឹងវាពីរនាក់ ។

សុជាៈ ម្នាក់ទៀតឈ្មោះអីគេ?

ម៉េតៈ អា រត្ន ។

សុជាៈ ចុះពេលគេដក គេដក រត្ន ហ្នឹងមៅដែរ?

ម៉េតៈ គេដកទាំងអស់ ។ ដកមៅទាំងអស់អញ្ចឹង គេយកមកឲ្យរៀនសូត្រនៅសាលាបច្ចេកទេសតាខ្មៅហ្នឹងណាស់ ។

សុជាៈ កាលហ្នឹងមានពីណាគេអ្នកបង្រៀន?

ម៉េតៈ កាលហ្នឹងវាមាន ថែម, យ៉ែម ហើយ ប៉េង ហើយពីណាមួយទៀត រុន ។

សុជាៈ ប៉េង ហ្នឹងឈ្មោះអី ប៉េង?

ម៉េតៈ អ្ហូ! ប៉េង ហ្នឹងគាត់ចាស់ហើយ ។ មិនមែន ប៉េង នៅទួលស្លែងទេ ។

សុជាៈ មិនមែន ឡេង ប៉េងទេ?

ម៉េតៈ បាទ ។

សុជាៈ គាត់ចាស់ៗហើយអ្ហេះ?

ម៉ែតៈ គាត់ចាស់ៗហើយ ។

សុជាៈ គេបង្រៀនពួកពូហ្នឹងគេបង្រៀនម៉េចខ្លះ?

ម៉ែតៈ និយាយទៅគេបង្រៀន យើងមានបង្រៀននយោបាយអញ្ចឹងទៅ ដល់ចប់នយោបាយគេឲ្យរៀនបច្ចេកទេសខាងសង្គ្រាមណាស់ ។

សុជាៈ ធ្វើម៉េចខ្លះហ្នឹង?

ម៉ែតៈ អូ្ហ! ដូចថាយើងមានទ័ពផ្សេងពីគ្នា យើងវៃតាមអាដេងគ្រង់សេ ដូចថាម្នាងរំដោះ ម្នាងលន់ណុលអញ្ចឹងទៅណា គេឲ្យយើងរៀនបច្ចេកទេសហ្នឹងឲ្យ និយាយទៅឲ្យវាជ្រាជ្រះទៅ ក្រែងលោថាមានសង្គ្រាមណាទៀត ។

សុជាៈ ដកទៀត?

ម៉ែតៈ ដកទៅទៀត ។

សុជាៈ អាហ្នឹងគេដាក់ហ្នឹង ដាក់នៅសាលាឲ្យរៀន គេដាក់នៅក្នុងកងពលណា?

ម៉ែតៈ កងពល១២ ។

សុជាៈ កងពល១២ ៧០៣ហ្នឹង?

ម៉ែតៈ បាទ! អត់ទាន់បានដល់៧០៣ទេ ។

សុជាៈ អាហ្នឹងមិនអាចដកពួកនិរតីអីមៅរៀនអីអត់បានទេ?

ម៉ែតៈ អត់បានទេ ។

សុជាៈ និរតីគេរៀនខាងនិរតីគេនោះផ្សេងទៅ?

ម៉ែតៈ បាទ! ខាងផ្សេងគ្នា ។

សុជាៈ ហើយដល់ពេលដែលមៅរៀននៅតាខ្មៅនេះ មានគ្នាប៉ុន្មាននាក់ដែរ?

ម៉ែតៈ រៀននៅតាខ្មៅនេះ បើនិយាយទៅច្រើនណាស់ រាប់រយនាក់ ។

សុជាៈ កាលហ្នឹងនៅម្តុំណាតាខ្មៅ?

ម៉ែតៈ នៅម្តុំហួសពីគល់ស្ពានចូលទៅក្នុងទៅ ។

សុជាៈ ស្ទឹងជ្រៅ ស្ទឹងអីហ្នឹង?

ម៉ែតៈ បាទ! នៅត្រើយខាងជើង ។

សុជាៈ ហើយ ប្រធានសាលាហ្នឹងឈ្មោះអីគេ?

ម៉ែតៈ យ៉ែម ។

សុជាៈ កាលគេរៀនសូត្រនយោបាយ គេរៀនយ៉ាងម៉េចខ្លះទៅ?

ម៉េត: រៀនសូត្រនយោបាយ គេនិយាយអំពីការយកចិត្តទុកដាក់នៅក្នុងការរៀនសូត្របច្ចេកទេស គេឲ្យយើងខំយកចិត្តទុកដាក់អំពីការងារបច្ចេកទេសរបស់គេហ្នឹង ។

សុជា: ហើយគេអត់មាននិយាយរឿងមនោគមវិជ្ជាអីឲ្យយើង?

ម៉េត: ទោះគេនិយាយក៏ខ្ញុំភ្លេចអស់ដែរឥឡូវនេះ មិនអត់ទេដែលគេនិយាយ ប៉ុនខ្ញុំពីមុនដឹងស្រាប់ហើយ រៀនអីក៏មិនសូវចូលដែរ ។

សុជា: ហើយគេឲ្យរៀនសូត្រប៉ុន្មានខែដែរ?

ម៉េត: អ្ហូ! រៀនហ្នឹងបើនិយាយទៅ ចូល៨ខែដែរ ។

សុជា: ពីឆ្នាំណាដែរ នៅក្នុងឆ្នាំណាដែរ?

ម៉េត: នៅក្នុងឆ្នាំ៧៥ មៅ៧៦ ។

សុជា: ពី៧៥ មៅ៧៦ ខែប៉ុន្មាន ៧៥ហ្នឹង?

ម៉េត: អត់ដឹងខែទេ ខ្ញុំហ្នឹង ចូល

សុជា: ប្រហែលជាចូលភ្នំពេញបានប៉ុន្មានខែ បានគេដកពូមៅ ។

ម៉េត: រំដោះចូលភ្នំពេញហ្នឹងអត់បានពីរខែទេ ប្រហែលមាខែហ្នឹង ។

សុជា: គេដកឲ្យមៅរៀនហ្នឹង?

ម៉េត: បាទ! បានមាខែ ។

សុជា: ចុះដល់ពេលរៀនចប់?

ម៉េត: ដល់ពេលរៀនចប់ បានគេបញ្ជូនខ្ញុំទៅទួលស្វែង ។

សុជា: ចុះកាលរៀននៅហ្នឹងគេមានចែកប្រធានក្រុមទេ?

ម៉េត: គេចែក ។

សុជា: ប្រធានក្រុមពូឈ្មោះអីដែរ?

ម៉េត: ប្រធានក្រុមហ្នឹង?

សុជា: បាទ!

ម៉េត: ប្រធានក្រុមមានអា វុន អាអី ។

សុជា: ចុះកងហាកងអី កាលហ្នឹងគេចែកនៅកងហា កងអីហ្នឹង?

ម៉េត: គេចែកអស់ហើយ ។

សុជា: ចុះកងហាពីណាគេទៅ?

ម៉េត: ខ្ញុំភ្លេចអស់ហើយ

សុជាៈ  កងរយ?

ម៉េតៈ  កងរយហ្នឹងបើនិយាយទៅ វាមានពួកអាអ្នកបង្ហាត់ហ្វឹកហ្វឺនហ្នឹងទេ អ្នកបង្រៀនៗហ្នឹង ។

សុជាៈ  ដូចឈ្មោះ យ៉ែម ឈ្មោះ ប៉េង ឈ្មោះអីហ្នឹងអ្ហេះ?

ម៉េតៈ  បាទ!

សុជាៈ  ហ្នឹងសុទ្ធតែថ្នាក់ដឹកនាំសាលាហ្នឹងហើយ?

ម៉េតៈ  ថ្នាក់ដឹកនាំសាលា ។

សុជាៈ  ចុះដល់ចេញពីហ្នឹងទៅ គេឲ្យទៅណាទៀត?

ម៉េតៈ  ដល់ខ្ញុំចេញពីហ្នឹងទៅ គេឲ្យខ្ញុំទៅទួលស្លែង ។

សុជាៈ  កាលហ្នឹងចេញទៅទួលស្លែងឆ្នាំណា?

ម៉េតៈ  ចេញទៅទួលស្លែងឆ្នាំ៧៧ ។

សុជាៈ  កាលហ្នឹងទួលស្លែងមានជាលក្ខណៈយ៉ាងម៉េចដែរ?

ម៉េតៈ  ទួលស្លែងហ្នឹងអ្ហេះ?

សុជាៈ  បាទ!

ម៉េតៈ  ចូលដល់មុនដំបូងនៅក្នុងរបង គេរៀបជារបងសង្កសីអ្ហាស់ ។

សុជាៈ  កាលហ្នឹងពូទៅទួលស្លែងហ្នឹង គេរៀបជារបងជាគុកហើយហើយ ។

ម៉េតៈ  បាទ! រៀបមិនទាន់ជាត្រឹមត្រូវទេ ។ គេគ្រាន់តែរៀបជារបងជុំវិញហើយអស់ ប៉ុនក្នុងគេមិនទានរៀបជាសំខាន់ៗទេ ។

សុជាៈ  ហើយពូ មានដឹងថាទួលស្លែងបង្កើតឡើងនៅក្នុងឆ្នាំណាដែរ?

ម៉េតៈ  ខ្ញុំអត់ដឹងបង្កើតនៅក្នុងឆ្នាំណាទេ ។

សុជាៈ  ដែលពូទៅដល់មានហើយៗ ៧៧ហ្នឹង?

ម៉េតៈ  បាទ! មានហើយៗ

សុជាៈ  ហើយគ្នាពូដែលចេញពីតាខ្មៅទៅហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

ម៉េតៈ  ចេញពីតាខ្មៅទៅមានគ្នា៥០នាក់ សុទ្ធតែនិរសារទាំងអស់

សុជាៈ  ពូមានចាំអ្នកទៅជាមួយទេ មានឈ្មោះអីខ្លះដែរ?

ម៉េតៈ  អ្នកទៅជាមួយហ្នឹងខ្ញុំ ឲ្យខ្ញុំឆ្លើយភ្លាមៗក៏ចាំអត់អស់ដែរ ។ អ្នកនៅជាមួយស្លាប់អស់ហើយ បើនិយាយទៅនៅតែ ឌុច ខ្ញុំ ប៉េងគ្រី ដូចអា ហ៊ាង អាអីហ្នឹងវានៅប៉ុន្មាន មានតែប៉ុន្មាននាក់ហ្នឹងទេដែលនៅ ។

សុជាៈ ពូកហ្នឹងភាគច្រើនទៅពីខាងណាទៅដែរ?

ម៉េតៈ ខាងយើងខេត្តកណ្តាល ស្រុកស្អាង កោះធំហ្នឹង ។

សុជាៈ ចុះពូមានដឹងពេលដែលទៅធ្វើនៅទួលស្លែងហ្នឹង មានអ្នកដែលមកពីខេត្តផ្សេងៗទៀតទៅធ្វើដែរ

ម៉េតៈ មាន

សុជាៈ ខេត្តណាខ្លះពូមានដឹងទេ មានសួរគេទេ?

ម៉េតៈ មានតាកែវ ខ្ញុំដឹងតាកែវ មានប៉ូ, ទុយ ។

សុជាៈ ទុយ ទុន ទុយ ហ្នឹងអ្ហេះ?

ម៉េតៈ បាទ! អាទុយ អ្នកសួរចម្លើយហ្នឹង ខាងកំពង់ឆ្នាំង អាហ្នឹងខ្ញុំដឹងបីខេត្ត ទាំងខេត្តខ្លួនឯងនេះណា

សុជាៈ បាទ!

ម៉េតៈ កំពង់ឆ្នាំងមាន អាទិត្យ ណាន ឈិន អាអីសុទ្ធតែពួកគេអន្ទឹនៗ ខ្ញុំពិបាកចំណាំណាស់ ។

សុជាៈ កំពង់ឆ្នាំងមានស្គាល់ឈ្មោះ ឡាច មាន អីទេ?

ម៉េតៈ ឡាច មាន អត់ស្គាល់ ។ អត់ទេការងារខាងហ្នុងវាខុសគ្នា ពិបាកទាក់ទងគ្នា ។

សុជាៈ តែម៉ាបុគ្គលិកអ្នកធ្វើការនៅក្នុង ស-២១ ប្រហែលគ្នាប៉ុន្មាននាក់?

ម៉េតៈ ទេ អត់ចាំទេ មានគ្នាច្រើនណាស់ ។

សុជាៈ ហើយមានចែកជាប៉ុន្មានផ្នែកដែរ តាមពូដឹង?

ម៉េតៈ ចែក វាមានអ្នកយាម មានអ្នកសួរចម្លើយ ហើយមានអ្នកចាប់អ្នកចងអីផ្សេងទៀត ។

សុជាៈ ចុះពូនៅខាងណា?

ម៉េតៈ ខ្ញុំខាងការពារ ។

សុជាៈ ហើយក្រុមកងការពារមានគ្នាប៉ុន្មាននាក់ដែរ?

ម៉េតៈ កងការពារ បើនិយាយទៅខ្ញុំវាធ្វើខាង ផ្នែកគេខាងក្នុងគេយាម ខ្ញុំយាមនៅខាងក្រៅម្នាក់ឯង ។

សុជាៈ អញ្ចឹងយាមហ្នឹងប៉ុន្មានជាន់ដែរ?

ម៉េតៈ ខ្ញុំយាមជាន់ទី២ ។ ប៉ុនខ្ញុំយាមអត់មាននៅក្នុងអាគារគេទេណាស់ ខ្ញុំអត់ដែលចូលទេអាគារ ។

សុជាៈ ពូយាមនៅខាងណា?

ម៉េតៈ នៅខាងត្បូងអាគារ នៅតាមផ្ទះមួយៗដូចផ្ទះយើងអញ្ចឹងទៅណា ។ ផ្ទះគេដូចផ្ទះអ្នកធំៗ មិនដឹងអ្នកធំពីណាមកទេ យើងអត់ដឹងទេ ។

សុជាៈ យាមនៅក្នុងគុកដែរ ឬក៏?

ម៉េតៈ នៅក្នុងគុកដែរ ប៉ុន្តែនៅក្នុងគុកហ្នឹងមានអ្នកតូចមានអ្នកធំ ។

សុជា៖ បាទ! ហើយពូឃាមផ្ទាល់ជាមួយអ្នកជាប់គុកហ្នឹងហ្នង?

ម៉េត៖ បាទ!

សុជា៖ នៅអាគារខាងណាដែរ?

ម៉េត៖ នៅខាងត្បូងអាគារ ជិតរបង យើងទៅចំឡានទឹក ។

សុជា៖ ហើយអាគារខាងត្បូងគេដាក់?

ម៉េត៖ ខាងហ្នឹងអត់មានអាគារទេ ផ្ទះហ្នង ដូចផ្ទះថ្មយើងដូចនៅអញ្ចេះៗ ។

សុជា៖ អាទួលស្លែងយើងហ្នឹង មិនមានអញ្ចេះពូ វាមានអាគារអញ្ចេះ ខាងជើង ខាងត្បូង !

ម៉េត៖ វាមាន៤ល្វែង

សុជា៖ ហើយខាងណេះ ។ ហើយអាគារកណ្តាល ហើយច្រកចូលអត់មានអាគារទេ អាគារខាងណេះមួយដែរអញ្ចឹង?

ម៉េត៖ ចាំមើលអាគារវាមាន៤ល្វែង មានអញ្ចេះ មានអញ្ចេះ មានអញ្ចេះ មិនអញ្ចឹង អានេះមិនខ្វាងទ្វារចូលចំនេះ ហើយខ្ញុំ ហើយនេះរបងលួស ហើយខ្ញុំម៉ៅឃាមនៅខាងត្បូងអាគារនេះ ។ ផ្ទះនៅក្នុងរបងដូចគ្នាដែរ ប៉ុនវាអត់នៅក្នុងអាគារណាស់ ។

សុជា៖ បាទ!

ម៉េត៖ នៅជាប់អាគារហ្នឹង ។

សុជា៖ អញ្ចឹងអ្នកទោសដែលពូឃាមហ្នឹង ច្រើនអ្នកទោសរបៀបម៉េចដែរ?

ម៉េត៖ សួរអញ្ចឹង ក៏អត់នេះដែរ សួរអញ្ចឹងមានតែទៅសួរអ្នកសួរចម្លើយទេ ។

សុជា៖ កាលហ្នឹងអ្នកទោស យើងក្រោយម៉ៅដឹងថាមាន ចាប់ពួកលន់ នល់អី គ្រូបង្រៀនអី គ្រូពេទ្យអី

ម៉េត៖ អត់មានទេ! សុទ្ធតែទព័គ្នាឯងហ្នង ។

សុជា៖ ហើយការចាប់ហ្នឹង យកទៅដាក់ហ្នឹងនៅក្នុងឆ្នាំណាទៅ?

ម៉េត៖ នៅក្នុងឆ្នាំ៧៨ ។

សុជា៖ តែកាលហ្នឹងទព័ហ្នឹងច្រើនម៉ៅពីខាងណាដែរ?

ម៉េត៖ ទព័ហ្នឹង សុទ្ធតែទព័គ្នាឯងដែរ ដូចមេខ្ញុំ តាឈុន តាអីហ្នឹង អាដែលៗ

សុជា៖ គេចាប់ម៉ៅដែរ?

ម៉េត៖ បាទ! ហើយមិនដឹងខ្សែរយៈចេញពីណាៗម៉ៅយើងវាអត់ដឹងដែរហ្នឹង ។

សុជា៖ ចុះ ឈុន ហ្នឹងចាប់ម៉ៅចូលទួលស្លែងហ្នឹងដែរ?

ម៉ែតៈ  មិនដឹងចូលទួលស្លែង មិនដឹងចូលកន្លែងណា ព្រោះថាយើងដូចថាអន្តរក្សគេដែរ គេអ្នកធំ គេចាប់មៅ គេមិនឲ្យយើងយាមអ្នកហ្នឹងដដែលទេ អត់មានទេ។ ដូចថាមៅពីណាពីណីទៅវិញទេ គេឲ្យយើងយាមអ្នកហ្នឹងផ្សេងទេ។ មិនខុសពីយើងភ្ជួរគោរអាដែលៗទេ គេម៉េចឲ្យភ្ជួរ ។

សុជាៈ  ហើយពូយាម ពូមានដែលប៉ះអ្នកទោសណាដែលពូស្គាល់ទេ?

ម៉ែតៈ  អត់ស្គាល់ ។

សុជាៈ  សុទ្ធតែប្លែកៗ?

ម៉ែតៈ  ប្លែក ។

សុជាៈ  តែពូអាចដឹងថាអ្នកហ្នឹងមៅពីភូមិភាគណាដែរ?

ម៉ែតៈ  ភូមិភាគវាមានគ្រប់ភូមិភាគណោះ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ហ្នឹងតំបន់ មិនដឹងភូមិភាគអីអត់មានទេ ។

សុជាៈ  អត់ហ៊ានសួរគេទេ?

ម៉ែតៈ  អូរ! អត់ហ៊ានទេ គ្រាន់តែអើតមើលឯកសណ្ឋានទេ គេដកដូចស្តែអញ្ចឹង ។

សុជាៈ  ពូបានតែយាមហ្នឹងទេ?

ម៉ែតៈ  បាទ!

សុជាៈ  យាមអ្នកទោសប៉ុន្មាននាក់ដែរ?

ម៉ែតៈ  ខ្ញុំយាមតែម្នាក់ទេ តតួរអញ្ចឹងហ្មង ប៉ុនគ្រាន់តែថាក្នុងម៉ាយប់ម៉ាថ្ងៃហ្នឹងវាមានគ្នាពីរនាក់ វាមានយប់ មានថ្ងៃ ។ ដោះដូរគ្នាប៉ុណ្ណឹង ។

សុជាៈ  អ្នកយាមយប់ផ្សេង អ្នកយាមថ្ងៃផ្សេង ហើយឆ្លាស់គ្នាទេអ្នកយាម?

ម៉ែតៈ  បាទ! ឆ្លាស់គ្នា ។

សុជាៈ  ហើយឧបមាថាអ្នកយាមហ្នឹងគេចង់ គេមានលក្ខណៈឯកសណ្ឋាណបែបម៉េចដែរ?

ម៉ែតៈ  អ្នកយាមបើនិយាយទៅ យើងគ្រាន់តែការពារកុំឲ្យអ្នកទោសហ្នឹងធ្វើសកម្មភាព ឬមួយបោកក្បាល ឬមួយសម្លាប់ខ្លួន តែប៉ុណ្ណឹងទេ។ រួចឲ្យយើងទៅបំពានលើអ្នកទោសក៏អត់បានដែរ ។ មានគេអ្នកផ្សេងមៅសួរ ។

សុជាៈ  គេដាក់ម៉េច?

ម៉ែតៈ  ជួនកាលអ្នកទោសណាដែលខ្លាំងគេដាក់ខ្នោះជើង ។

សុជាៈ  អញ្ចឹង

ម៉ែតៈ  បើខ្សោយគេគ្រាន់តែដាក់ច្រវ៉ាក់ ។

សុជាៈ  អាចដើរបាន?

ម៉េតៈ បាទ! អាចនៅក្នុងបន្ទប់ហ្នឹងបាន ។

សុជាៈ បន្ទប់ដែលគេដាក់អ្នកទោសហ្នឹងធំទេ?

ម៉េតៈ ប៉ុនអាផ្ទះ ដូចផ្ទះថ្មហ្នឹង ។

សុជាៈ ធំៗដែរ?

ម៉េតៈ បាទ! ធំៗ ។ ដាក់ក្រាលកន្ទេលអញ្ចឹងទៅ ។

សុជាៈ ពូអាចដឹងថាអ្នកដែលមៅជាប់ទោសហ្នឹងឋានៈត្រឹមណា? ថ្នាក់កងពល ឬថ្នាក់ភូមិភាគ?

ម៉េតៈ ដូចខ្ញុំគ្រាន់តែមើលមុខមាត់ យ៉ាងអន់ត្រឹមថ្នាក់ចៅហ្វាយស្រុកអី ឬគណៈតំបន់ ហើយហ្នឹងភូមិភាគអីអញ្ចឹងដែរ ។

សុជាៈ ប៉ុនឲ្យដឹងថាមៅ ពីណាយើងអត់ដឹងទេ?

ម៉េតៈ អត់ដឹងទេ ។ យើងហ៊ានសួរអត់បានទៀត បើអ្នកទោសគេថា បងអ្នកយាមសួរខ្ញុំអញ្ចេះៗៗ អ្នកសួរចម្លើយរាយការណ៍ដល់អ្នកធំ ខ្ញុំត្រូវនេះហើយ ។ ថាទៅហ្នឹងដូចអ្នកគ្រប់លក្ខ័ណ៍អញ្ចឹង ប៉ុនគ្រាន់តែ បម្រើបាយ បម្រើទឹក បម្រើងកន្តោរបត់ជើង ។

សុជាៈ ខ្ញុំសួថារពេលដែលអ្នកទោសហ្នឹងហូបបាយយ៉ាងម៉េចទៅ?

ម៉េតៈ ពេលហូបបាយ មានគេអ្នកបម្រើបាយយកមកឲ្យ ។ ដលគេយកមកឲ្យ យើងដាក់ឲ្យមានទឹកមានអីអញ្ចឹងទៅ ។

សុជាៈ ហើយបាយអ្នកទោសហ្នឹងមានអីខ្លះទៅ?

ម៉េតៈ បើនិយាយទៅអត់ខុសពីបាយអ្នកយាមហ្នឹងប៉ុន្មានទេ ប៉ុនតែសម្លវាអាចខុសគ្នាណាស់

សុជាៈ បាទ! មួយថ្ងៃ គេឲ្យអ្នកទោសហ្នឹងប៉ុន្មានពេលដែរ?

ម៉េតៈ ២ពេល ព្រឹក ល្ងាច ដូចគ្នា ប៉ុនគ្រាន់តែមួយសម្លដើមចេក មួយសម្លត្រីខអញ្ចឹងទៅណា ។ អ្នកទោសបើនិយាយទៅវាអ្នកទោសហើយអ្នកយាមដូចជាមួយគ្នាទេ ។ ខ្ញុំអ្នកយាមដូចជាមួយអ្នកទោសដែរហ្នឹង អ្នកទោសយាមអ្នកទោសអាហ្នឹងណាស់ ។

សុជាៈ បាទ! ចុះអ្នកយាមគុកមានអ្នកយាមពីខាងក្រៅរបងដែរ?

ម៉េតៈ មានទៀត ។

សុជាៈ ប៉ុន្មានជាន់ដែរ?

ម៉េតៈ ទេរបងហ្នឹងបើនិយាយទៅ វាមានតែម៉ាជាន់ទេ មានតែរបងលួស ។

សុជាៈ ហើយនៅពេលដែលលោកពូយាមនៅហ្នឹង មានដែលឃើញអ្នកទោសណាមួយដែលចង់សម្លាប់ ឬក៏ស្រែក ឬនិយាយពាក្យអីផ្សេងៗទេ?

ម៉ែត: អត់! ដល់ពេល គ្រាន់តែពួសួរតែពេញកន្លែងទាំងអស់ ។ ដល់ពេលដែលគេមោចូលសួរចម្លើយ ហ្នឹង គេឲ្យយើងចេញមោក្រៅហើយ គេបិទទ្វារគ្រឹប ។

សុជា: អញ្ចឹងគេមោសួរ សួរនៅក្នុងបន្ទប់ដែលឃុំឃាំងហ្នឹងហ្នង?

ម៉ែត: បាទ!

សុជា: អត់មានយកអ្នកទោសចេញទៅខាងក្រៅទេ?

ម៉ែត: អត់ទេ! កន្លែងខ្លះគេយកទៅតើ ។ ដល់ពេលកំណត់មោ គេយកមោវិញ ។

សុជា: ចុះកន្លែងអ្នកទោសពួ ពូយាមបានប៉ុន្មាននាក់ដែរមោដែលទៅយាមហ្នឹង?

ម៉ែត: ខ្ញុំ យាមបើគិតទៅ មិនខ្ញុំរាប់ទៅ រាប់មិនឈ្នះដែរ ។

សុជា: អ្នកទោសច្រើនដែរអញ្ចឹង?

ម៉ែត: បាទ!

សុជា: ចុះអ្នកទោសដែលយកមោអញ្ចឹង?

ម៉ែត: មានចេញ មានចូលៗ ។

សុជា: អ្នកទោសដែលយកមោដាក់ហ្នឹងបានរយៈពេលប៉ុន្មានដែរ បានគេយកទៅបាត់ទៅ?

ម៉ែត: ខ្លះបាន២ខែ ម៉ាខែ ហើយ ខ្លះដល់ត្រូវនេះ អាហ្នឹងជួនកាលគេដោះដូរគ្នាទៀត យកអ្នកផ្សេង មកឲ្យនៅហ្នឹង យកអាមួយទៅនោះទៀត ។

សុជា: ហើយអ្នកទោសគេយកទៅសួរចម្លើយប៉ុន្មានដងបានបាត់ខ្លួន?

ម៉ែត: សួរចម្លើយ បើនិយាយទៅមិនដឹងប៉ុន្មានដងទេ ខ្ញុំពិបាកដឹងរឿងដងហ្នឹងដែរ ព្រោះអីខ្ញុំនៅយាម ហ្នឹង ជួនអីគេមោសួររាល់តែថ្ងៃ ។

សុជា: ការសួរចម្លើយហ្នឹង ខ្ញុំសួរពូមួយទៀត ជួនកាលគេមោសួរនៅកន្លែងបន្ទប់ហ្នឹងតែម្ដង ជួនកាល គេយកអ្នកទោសចេញ?

ម៉ែត: ដែលខ្ញុំនៅកន្លែងហ្នឹង គេអត់ដែលយកចេញទេ គេមោសួរនៅហ្នឹង ។

សុជា: ដែលគេយកអ្នកទោសពូចេញទៅសួរក្រៅទេ ទៅសួរបន្ទប់ផ្សេងអ្នកស់?

ម៉ែត: ហ្នឹងអត់ទេ ។

សុជា: គេអ្នកមោសួរ គ្នាគេប៉ុន្មាននាក់ដែរ?

ម៉ែត: ជួនកាលមោម្នាក់ ពីរនាក់ អាហ្នឹងសុទ្ធតែអ្នកធំៗគេមោសួរហើយ ។

សុជា: ពីណាខ្លះ ឈ្មោះអី?

ម៉ែត: ឌុច អីហ្នឹង ។

សុជា៖ ឪុច ធ្លាប់មៅសួរអ្នកទោសផ្ទាល់ដែរ?

ម៉េត៖ បាទ!

សុជា៖ ចុះផ្សេងក្រៅពី ឪុច?

ម៉េត៖ ទុយ អាហ្នឹងតាមដំណើរខបមាថា មុនដំបូងអា ទុយ វាអ្នកសួរអញ្ចឹង ដល់វាសួរមិនចេញ អញ្ចឹងទៅ ឪុច វាមៅ ហ្នឹងអាច ។

សុជា៖ ហើយដល់ពេល ឪុច មៅអញ្ចឹង ឪុច សួរមិនចេញទៀត ធ្វើម៉េចទៅ?

ម៉េត៖ សួរមិនចេញគេវ៉ៃ ។

សុជា៖ ពីណាអ្នកវ៉ៃ?

ម៉េត៖ អា ទុយ

សុជា៖ ចុះ ឪុច ដែលវ៉ៃ?

ម៉េត៖ ឪុច ហ្នឹងឃើញ ក្រែងលោសួរគេណាផ្សេងទៀតមិនដឹងទេណា ។

សុជា៖ បាទ!

ម៉េត៖ បើកន្លែងបន្ទប់ខ្ញុំគ្រាន់តែឃើញធាក់ទេ ។ ធាក់ពីរបីជើងដើរចេញទៅ ហើយឲ្យអានោះមៅទៀត

សុជា៖ ឲ្យនរណាមៅ?

ម៉េត៖ ឲ្យអា ទុយ មៅ ។

សុជា៖ ហើយកន្លែងពួយាម ពេលដែលគេកំពុងសួរចម្លើយគេចាក់សោរ ?

ម៉េត៖ ចាក់ ។

សុជា៖ ហើយតើយើងមើលឃើញ ស្តាប់ឮទេ?

ម៉េត៖ អូរ អាហ្នឹងខ្ញុំស្តាប់ឮ ខ្ញុំលួចមើលតាមបង្អួតដែរ ។ ជួនកាលគេមៅដល់គេថាមិត្តឯងចេញ ។ គេបិទទ្វារគ្រឹបអញ្ចឹង យើងនៅក្បែរបង្អួច អត់ហ៊ានចេញចោលគេទៀត ខ្លាចក្រែងលោគេធ្វើសកម្មភាពទៅ វាអាច ។

សុជា៖ អញ្ចឹងពូរយៈពេលដែលគេសួរចម្លើយម្តងៗ ប៉ុន្មាននាទីដែរពូ?

ម៉េត៖ យី! សួរ អ្នកសួរចម្លើយអ្នកទោសអ្ហេះ?

សុជា៖ បាទ! ពេលគេសួរចម្លើយអ្នកទោសប៉ុន្មាននាទីដែរ?

ម៉េត៖ យី សួរយូរដែរហ្នឹងណាស់ អត់មានរឿងនាទីទេ ជួនកាលមៅ៉ង កន្លះមៅ៉ង ជួនកាលមៅ៉សួរនៅហ្នឹង ជួនកាលមៅតាំងពីបាយព្រឹកហើយ មៅដល់បាយថ្ងៃហើយក៏មានដែរ ។

សុជា៖ ហើយមាថ្ងៃគេសួរប៉ុន្មានដងដែរ?

ម៉េតៈ  ម៉ាងៃដួនណាគេសួរម្តង  សួរពីរដងអី ។

សុជាៈ  ចុះម៉ាអាទិត្យគេសួរប៉ុន្មានដងអ្នកទោសមួយ?

ម៉េតៈ  អត់ទៀងទេ  ដួនកាលគេមៅដូរយាម  ខ្ញុំយាមថ្ងៃអញ្ចឹង  ខ្ញុំទៅសម្រាកវិញ ។  យប់  គេយាមថ្ងៃ ខ្ញុំទៅសម្រាកយប់វិញ  វាអត់ទៀងទេ  ដួនកាលអ្នកទោសហ្នឹងនៅជាមួយខ្ញុំអញ្ចឹង  ដួនណាគេ អ្នកយាមថ្ងៃគេយកទៅបាត់ទៅ  ខ្ញុំក៏ផ្អាកទាំងអស់គ្នា ។  ដួនកាលគេយកពីណាមៅមកដាក់ហ្នឹង មួយទៀត ។

សុជាៈ  ចុះកាលហ្នឹងអ្នកទោសម្នាក់ដែលជាប់នៅហ្នឹង  គេសួរប៉ុន្មានដងដែរបានបាត់ខ្លួនទៅ?

ម៉េតៈ  ដួនកាលសួរបួនដប់ដងអីអញ្ចឹងទៅ ។

សុជាៈ  យកទៅបាត់ទៅ ។

ម៉េតៈ  បាទ!  ដួនកាលខ្ញុំយាមថ្ងៃ  គេយាមយប់ ។  យប់ហ្នឹងគេយកទៅបាត់ទៀត ។

សុជាៈ  ក្រុមសួរចម្លើយមានគ្នាប៉ុន្មាននាក់ដែរ?

ម៉េតៈ  ក្រុមសួរចម្លើយខ្ញុំអត់ដឹង  ខ្ញុំដឹងតែអ្នកដែលមៅសួរនៅកន្លែងខ្ញុំទេ ។

សុជាៈ  មានឈ្មោះ  ឌុច  ឈ្មោះ?

ម៉េតៈ  បាទ!  ឌុច  អាទិត្យ  ណាន  ឈិន  អីអញ្ចឹងទៅណា ។

សុជាៈ  បាទ!

ម៉េតៈ  តាមផ្នែក  តាម ។

សុជាៈ  ឈិន  ឈ្មោះអី  ឈិន?

ម៉េតៈ  អត់ស្គាល់អាហ្នឹងឈ្មោះអី  ឈិន  ដង ។

សុជាៈ  ចុះ  ទុយ?

ម៉េតៈ  ទុយ  ហ្នឹងក៏អត់ស្គាល់ ។  អត់ស្គាល់ជីតាគេទេ ។

សុជាៈ  ហើយក្រុមសួរចម្លើយផ្សេង  ក្រុមការពារផ្សេងទៀត?

ម៉េតៈ  បាទ!  ក្រុមចាប់នោះផ្សេងទៀត ។  ខ្ញុំមិនដឹងថាពួកណាខាងចាប់ទេ  ខ្ញុំមិនដឹងខាងតាមភូមិភាគគេ ចាប់យកមកឲ្យមិនដឹងទេណា ។

សុជាៈ  ចុះពូការចេញចូលអ្នកទោសហ្នឹង  គេចេញចូលដាក់ឡានម៉េចខ្លះ?

ម៉េតៈ  ចេញចូលអ្នកទោស  យើងអត់ដឹងរឿងដាក់ឡានយកមកឲ្យទេ  ព្រោះខ្ញុំខាងយាមនេះដឹងតែយាម ទេ  អត់មានឲ្យ ។

សុជាៈ  ចុះពេលដែលគេយកអ្នកទោសមៅដាក់អញ្ចឹង  ?

ម៉េតៈ យកមកដាក់អញ្ចឹង គេបណ្ដើរមៅ ។

សុជាៈ ហើយគេមាន?

ម៉េតៈ ចងមុខ ក្រលំក្រមាំមៅជិតឈើង ក្រលំក្រមាំយើងគ្រប់មៅអញ្ចឹងណា អាមុខចង អា.....

សុជាៈ បណ្ដើរអ្នកទោសមៅ?

ម៉េតៈ បាទ!

សុជាៈ អាហ្នឹងក្រុមចាប់ចងគេបណ្ដើរមៅដាក់ក្នុងគុក គេបើក?

ម៉េតៈ គេបើកទ្វារអញ្ចឹង គេទៅហៅយើងកន្លែងសម្រាកមៅ ។

សុជាៈ ចុះដល់ពេលអាឡានដែលដឹកមៅ ពូដែលឃើញឡានដឹកទេ?

ម៉េតៈ ឡានដឹក សុទ្ធតែពួក អាពួកវា អាប៉េងត្រី អីហ្នឹង ព្រោះពួកវាសុទ្ធតែបើកឡាន អាហ្នឹង ។

សុជាៈ ប្រធានកងផ្នាក់ដឹកនាំនៅស-២១ហ្នឹងមានឈ្មោះអីខ្លះ?

ម៉េតៈ ខ្ញុំដឹងតែប្រធានក្រុម ដឹងតែ ហ៊ុយ ចំរើន ហើយហ្នឹងអា ស្រ៊ី ។ អាហ្នឹងនៅផ្នែកប្រធានក្រុម នៅការពារហ្នឹងណាស់ ។

សុជាៈ បាទ!

ម៉េតៈ នៅផ្នែកសួរខ្ញុំអត់ដឹងប្រធានក្រុមអីទេ ។

សុជាៈ ហើយចុះ ឌុច?

ម៉េតៈ ឌុច នោះគេប្រធាន ។

សុជាៈ ប្រធានធំ?

ម៉េតៈ ប្រធានធំនៅហ្នឹងហ្នង ។

សុជាៈ ហើយចុះបន្ទាប់ពី ឌុច មៅ?

ម៉េតៈ បន្ទាប់ពី ឌុច មៅ ហ៊ិរ ។

សុជាៈ ចុះបន្ទាប់ពី ហ៊ិរ មៅ?

ម៉េតៈ មាន ហ៊ិរ មានចាន់ មួយទៀត មិនដឹងម៉េចអីម៉េច គ្រាន់តែឃើញថាគេធ្វើការ សហការជាមួយគ្នាធំៗហ្នឹងទេ ។

សុជាៈ នៅក្នុងទួលស្លែងហ្នឹងពូមានដែលឃើញគេធ្វើទារុណកម្ម ដូចវ៉ៃ ដូចអីហ្នឹងដែរ?

ម៉េតៈ អត់! គ្រាន់តែឮសួរតែមាត់ទេ ។

សុជាៈ ឮសួរតែមាត់ទេ?

ម៉េតៈ បាទ! កន្លែងខ្ញុំ ខ្ញុំដឹងកន្លែងខ្ញុំ ។

សុជាៈ បើដឹង បើនៅកន្លែងពូ ពូធ្លាប់ឃើញគេធ្វើទារុណកម្ម?

ម៉េតៈ បាទ! ធ្លាប់ឃើញគេធ្វើទារុណកម្ម ។

សុជាៈ ពេលណាដែលគេធ្វើទារុណកម្ម?

ម៉េតៈ ពេលដែលមោះដល់ភ្លាម ដួនពេលដែលខ្ញុំនៅយាមអញ្ចឹង ដួនកាលខ្ញុំឃើញ ឌុច គេឡើងមោះ អញ្ចឹង ម៉េចយើងឆ្លើយមិនឆ្លើយ ។ អ្នកទោសគេឆ្លើយថា ខ្ញុំឆ្លើយរៀបរាប់ប្រាប់បងហើយ អស់ បងនៅធ្វើទារុណកម្មខ្ញុំទៀត ។ ឌុច គេធាក់ពីរបីជើងចុះទៅ ។

សុជាៈ ចុះទុយ មានដែលឃើញ ទុយ វៃទេ?

ម៉េតៈ ហើយទៅបានអា ទុយ វាឡើងមោះទៀត បានមោះសន្ទុះហ្នឹងបានអា ទុយ វាឡើងមោះទៀត ម៉េចយើងឆ្លើយមិនឆ្លើយ ម៉ិញហ្នឹងអ្នកធំណា៎ ។ ដល់ហើយអ្នកទោសក៏ថា ឲ្យខ្ញុំឆ្លើយម៉េចទៀត បង ខ្ញុំឆ្លើយរៀបរាប់ប្រាប់បង ខ្ញុំសរសេរជាឯកសារជូនបងហើយអស់ បងនៅធ្វើទារុណកម្មខ្ញុំ ដដែលៗ ។ ទុយ ក៏ទាញខ្សែភ្លើងមោះឆក់ ។ ឆក់ដាក់ស្នឹកត្រចៀកមួយ ប៉ាច់ៗ ដួលទាំងនៅលើ ឥដ្ឋហ្នឹងទៅ ។ ដឹងខ្លួនងើបមោះវិញ អាទុយ វាដាក់ទៀត ។ ដាក់ទៀត ក៏សន្លប់ដួលនៅឥដ្ឋហ្នឹង អាទុយ វានៅដើរចុះដើរឡើងហ្នឹង ។

សុជាៈ ចុះដែលឃើញគេធ្វើបាបអ្នកទោសដូចជាដកក្រចក ដកអីទេ?

ម៉េតៈ ខ្ញុំវាឃើញដែរ មិនមែនថាមិនឃើញទេ ប៉ុនតែដួនកាលយើងចាំអត់អស់ណាស៎ ។

សុជាៈ បាទ!

ម៉េតៈ ដល់ពេលអ្នកទោសដឹងខ្លួន អាទុយ វាទាញគួរគោទៀត វៃយរៗ អ្នកទោសក៏ស្រែក ខ្ញុំភ្ញាក់ ព្រលឹងអស់ហើយ និយាយក៏និយាយមិនចេញៗ ។

សុជាៈ ដល់ពេលសួរអស់ចិត្តទៅ ព្រលែងទៅវិញទៅ ហើយដល់មោះឯបាយមោះឯអី?

ម៉េតៈ ដាក់បាយ ហើយដល់ពេលគេមោះដូរអញ្ចឹងទៅ គេមោះដល់គេអ្នកយាមជាមួយយើង គេមោះដូរ យើងទៅហូបបាយ គេមោះដល់គេពិនិត្យឆែកខ្នើយមើល ជជុះខោខ្ញីអញ្ចឹងទៅ រកមើលក្រែង លោកមានម្ជុល ដែកគោលអីហ្នឹង អាហ្នឹងគេដូរអញ្ចឹង អាហ្នឹងគេប្រយត្ន័របស់គេណា៎ ក្រែង លោខ្លាចដែក ។

សុជាៈ ដល់ពូមោះមើលវិញ?

ម៉េតៈ បាទ! មើលដូចគ្នា ។

សុជាៈ ហើយកាលហ្នឹងពូមានដឹងថាអ្នកទោសដែលសួរចម្លើយត្រូវកម្មេច គេយកទៅកម្មេចនៅណាដែរ

ម៉េតៈ កម្មេច?

សុជាៈ បាទ!

ម៉េតៈ ព្រោះអីខ្ញុំអត់ដឹងរឿងគេយកទៅដាក់កន្លែងគុកក្រលៀតកន្លែងណា ។

សុជាៈ តែគេកម្មេច មិនមែនកម្មេចនៅក្នុងទួលស្លែងហ្នឹងទេ?

ម៉េតៈ ក្នុងទួលស្លែងហ្នឹងកាលដែលពួកសម្អាសន៍កន្លែងមុននោះ គេថា ឈ្មោះអាតឿៗ មួយនៅកំពង់ឆ្នាំនោះ វានិយាយឲ្យខ្ញុំបានដឹងដែរណាស់ ព្រោះវាខាងការពារខាងក្នុង ខាងអាគារ ដូចថាខ្មាំងបរទេសអញ្ចឹងយកទៅដុតចោលនៅថ្នល់លិចគុកទួលស្លែងអញ្ចឹងណា ដុតកម្មេចក្បែរធ្មើកង់ឡានអញ្ចឹងណា ។

សុជាៈ ខ្មោចបរទេសដូចជាជនជាតិអីខ្លះទៅ?

ម៉េតៈ ជនជាតិអាមេរិកាំង ។

សុជាៈ ហើយពូដឹងក្រោយមៅទៀតដែរ?

ម៉េតៈ បាស!

សុជាៈ សឿ ហ្នឹងដែលពូនិយាយប្រាប់?

ម៉េតៈ សឿ ហ្នឹងវានៅកំពង់ឆ្នាំងណោះ ។

សុជាៈ នៅរស់អ្ហេះ?

ម៉េតៈ នៅរស់ មៅនេះជាមួយខ្ញុំ ជាមួយ ប៉ាន់ ឫទ្ធី អីដូចគ្នា និយាយណាស់ ។ វាសម្អាសន៍ជាមួយប៉ាន់ ឫទ្ធី ណាស់ ។

សុជាៈ បាទ! ហើយពូ ចុះពូយាមអត់ដែលប៉ះអ្នកទោសបរទេសទេ?

ម៉េតៈ អត់ ។

សុជាៈ ចុះអ្នកទោសបរទេសគេដាក់កន្លែងណាដែរ?

ម៉េតៈ អ្នកទោសបរទេស ដូនកាលគេដាក់ផ្សេង កន្លែងគេផ្សេងទៀត រឿងខ្ញុំវាអត់សូវមាន អត់មានបរទេសទេ ។

សុជាៈ ចុះពូយាមមានដែលប៉ះអ្នកទោសស្រីទេ?

ម៉េតៈ អត់សុទ្ធ ។

សុជាៈ សុទ្ធតែបុរសៗ?

ម៉េតៈ សុទ្ធតែប្រុសៗ សុទ្ធតែអ្នកធំៗ ។ អានេះចំពោះខ្ញុំវាមិនដែលស្គាល់ ហ៊ូ នឹម, ហ៊ូ យន់ដែរទេណា ដូនកាលដូចស្រករៗ ហ៊ូ យន់, ហ៊ូ នឹម ហ្នឹងណា ។

សុជាៈ ក៏មានដែរ?

ម៉ែតៈ ក៏មានដែរ ហ្នឹងអ្នកធំៗ ហ្នឹងណា ។

សុជាៈ ចុះអ្នកដែលមានអាយុចាប់ពីប៉ុន្មានទៅដែលពូប៉ះយាមចំអ្ហាស់?

ម៉ែតៈ យាមចំ?

សុជាៈ បាទ!

ម៉ែតៈ អាយុសុទ្ធតែ ៤០ ឬ ៥០ ជួនកាលស្រុករៗខ្ញុំហ្នឹង ហ្នឹងឋានៈគេសុទ្ធតែកងពល វរសេនាធំអញ្ចឹងទៅ ភូមិភាគអីអញ្ចឹងទៅ ។

សុជាៈ ពូកាលហ្នឹងមានដែលឮឈ្មោះ ហ៊ូ យន់, ហ៊ូ នឹមទេ?

ម៉ែតៈ ខ្ញុំធ្លាប់ឮហើយ ។

សុជាៈ តែអត់ទាន់ស្គាល់មុខគាត់ទេ?

ម៉ែតៈ អត់ស្គាល់ ។

សុជាៈ តែក្រោយមៅមានដែលឮថា ហ៊ូ យន់, ហ៊ូ នឹម គេចាប់យកមកដាក់ហ្នឹងទេ?

ម៉ែតៈ អត់ដឹងថាចូលហ្នឹងដែរផង ។

សុជាៈ ចុះពេលណាបានពូដឹង?

ម៉ែតៈ ទើបតែយកទស្សនាវដ្ដីមកឲ្យខ្ញុំមើល បានដឹងថា ហ៊ូ នឹម, ហ៊ូ យន់ ដាក់ជាអក្សរខ្ញុំមើលឃើញដែរណាស់ ដូចតាម៉ុក, ដូចឌុច ដូចអៀង សារី, ខៀវ សំផន ខ្ញុំចេះតែមើលឃើញក្នុងទស្សនាវដ្ដី ។ ប៉ុនរឿងថាអ្នកធំៗខ្ញុំអត់ស្គាល់សុទ្ធ ។

សុជាៈ ទស្សនាវដ្ដីណាដែលពូមើលឃើញ?

ម៉ែតៈ ទស្សនាវដ្ដីរបស់ ប៉ាន់ ប៊ុទ្ធី យកមកឲ្យខ្ញុំ ។

សុជាៈ គេដាក់ចំណងជើងថាម៉េចដែរ?

ម៉ែតៈ គេដាក់អញ្ចឹងដែរ នេះ ទស្សនាវដ្ដី ស្វែងរកការពិត ដែរ ។

សុជាៈ អូរ! ហើយពេលដែលពូមើលទស្សនាវដ្ដីហ្នឹង ពូយល់ថាទស្សនាវដ្ដីហ្នឹងមានលក្ខណៈយ៉ាងម៉េចដែរ?

ម៉ែតៈ លក្ខណៈ គេស្រាវជ្រាវស្វែករកការពិត ដើម្បីទុកឲ្យក្មេងជំនាន់ក្រោយដែរ ។

សុជាៈ ហើយអីបានគេចាំបាច់ទុកឲ្យក្មេងជំនាន់ក្រោយបានដឹង?

ម៉ែតៈ អាហ្នឹង ខ្ញុំវាអត់សូវយល់ដែរ ព្រោះអីខ្ញុំវាចំណេះវិជ្ជាវាមិនទាន់ មិនចេះ ។

សុជាៈ ពូបានឃើញទស្សនាវដ្ដីហ្នឹងតាំងពីពេលណាមៅដែរ?

ម៉ែតៈ អ្ហូ! ខ្ញុំបានឃើញតាំងពីពេលមុនដំបូងឃើញ.......................

**ចប់កាសែ្សតទី១**